ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៣ លេខ ១៩ ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ១៩៩៥

# រាជកិច្ច

រួមមានៈ

- ច្បាប់
- ក្រម- ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្តាហ៍

# មាតិកា

## I ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


២៦.៥.១៩៩៥ – ព្រះរាជក្រឹត្យលេខ នស/រកត/០៥៩៥/៤៦ ៧៣៩

២៦.៥.១៩៩៥ – ព្រះរាជក្រឹត្យលេខ នស/រកត/០៥៩៥/៤៧ ៧៤២


## II ទីស្ដីការគណៈរដ្ឋមន្ត្រី

### ១— អនុក្រឹត្យ


២៧.៩.៥ – អនុក្រឹត្យលេខ ៤៤ អនក្រ.បក ស្ដីពីការបង្កើតបញ្ជាការដ្ឋានកងរាជអាវុធហត្ថ ខេត្ត មណ្ឌលគិរី–រតនគិរី ព្រះវិហារ និង ឧត្តរមានជ័យ ៧៤៣

៣០.៥.១៩៩៥ – អនុក្រឹត្យលេខ ៤៥ អនក្រ.បក ស្ដីពីការបង្កើតអគ្គលេខាធិការដ្ឋានអធិការកិច្ច .................................................. ៧៤៤

២៣.៥.១៩៩៥ – អនុក្រឹត្យលេខ ៦៣ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ៧៤៧

២៥.៥.១៩៩៥ – អនុក្រឹត្យលេខ ៦៤ អនក្រ.តត ស្ដីពីការលុបអនុក្រឹត្យលេខ ២៣ អនក្រ និង អនុក្រឹត្យលេខ ៨៤ អនក្រ.......................... ៧៤៨

២៧.៥.១៩៩៥ – អនុក្រឹត្យលេខ ៦៥ អនក្រ.តក ស្ដីពីការផ្ដល់មេដាយស្ថាបនាជាតិ ៧៥០

២៧.៥.១៩៩៥ – អនុក្រឹត្យលេខ ៦៦ អនក្រ.តត ស្ដីពីការផ្ដល់មេដាយស្ថាបនាជាតិ ៧៥១

២៩.៥.១៩៩៥ – អនុក្រឹត្យលេខ ៦៧ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ៧៥៣


### ២— សារាចរណែនាំ


២៥.៥.១៩៩៥ – សារាចរណែនាំលេខ ០២ សរណន ស្ដីពីការអនុវត្តច្បាប់សហលក្ខិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា...................... ៧៥៤

### ៣—ប្រកាស


| | | |
|---|---|---|
| ៤.៥.១៩៥៥ | ប្រកាសលេខ ២៩ ប្រក. បល ស្តីពីការបញ្ចូលក្របខ័ណ្ឌមន្ត្រីរាជការ | ៧៥៥ |
| ៩.៥.១៩៥៥ | ប្រកាសលេខ ៣៣ ប្រ. ក ស្តីពីការបង្កើតលេខាធិការដ្ឋានមេធាវីរបស់រាជរដ្ឋាភិបាល.................................... | ៧៥៧ |


# III ការងារបណ្តាក្រសួង

## ១—ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

### ប្រកាស


| | | |
|---|---|---|
| ៣.៥.១៩៥៥ | – ប្រកាសលេខ ១៣០ ប្រក. សហវ. ទ. រ ស្តីពីការតែងតាំងប្រធានគណៈកម្មាធិការឯកជនភាវូនីកម្ម សហគ្រាសសាធារណៈ.......... | ៧៥៩ |
| ១៥.៥.១៩៥៥ | – ប្រកាសលេខ ១៣៣ ប្រក. សហវ. ថ ស្តីពីការបង្វែរឥណទាន | ៧៦០ |
| ១៦.៥.១៩៥៥ | – ប្រកាសលេខ ១៣៥ ប្រក. សហវ. ថ ស្តីពីការបង្វែរឥណទាន | ៧៦៣ |
| ៣០.៥.១៩៥៥ | – ប្រកាសលេខ ១៣៦ ប្រក. សហវ. ថ ស្តីពីការបង្វែរឥណទាន | ៧៦៤ |
| ៣០.៥.១៩៥៥ | – ប្រកាសលេខ ១៤៣ ប្រក. សហវ. ថ ស្តីពីការបង្វែរឥណទាន | ៧៦៥ |
| ៣០.៥.១៩៥៥ | – ប្រកាសលេខ ១៤៥ ប្រក. សហវ. ថ ស្តីពីការបង្វែរឥណទាន | ៧៦៦ |
| ៣០.៥.១៩៥៥ | – ប្រកាសលេខ ១៤៦ ប្រក. សហវ. ថ ស្តីពីការបង្វែរឥណទាន | ៧៦៨ |
| ៣០.៥.១៩៥៥ | – ប្រកាសលេខ ១៤៧ ប្រក. សហវ. ថ ស្តីពីការបង្វែរឥណទាន | ៧៧០ |
| ៣០.៥.១៩៥៥ | – ប្រកាសលេខ ១៤៨ ប្រក. សហវ. ថ ស្តីពីការបង្វែរឥណទាន | ៧៧២ |
| ៣០.៥.១៩៥៥ | – ប្រកាសលេខ ១៥៣ ប្រក. សហវ. ថ ស្តីពីការបង្វែរឥណទាន | ៧៧៤ |
| ៣១.៥.១៩៥៥ | – ប្រកាសលេខ ១៥៥ ប្រក. សហវ. ថ ស្តីពីការបង្វែរឥណទាន | ៧៧៦ |


## ២—ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល

### ប្រកាស


| | | |
|---|---|---|
| ២៦.៥.១៩៥៥ | – ប្រកាសលេខ ៣៩៦ បល. ប្រក ស្តីពីការតែងតាំង និង ផ្ទេរភារកិច្ចមន្ត្រីរាជការ........................................ | ៧៧៩ |

២៦.៥.១៩៩៥ – ប្រកាសលេខ ៣៩៧ បណ.ប្រក ស្តីពីការតែងតាំងមន្ត្រីរាជការ ៧៨

២៩.៥.១៩៩៥ – ប្រកាសលេខ ៤០០ ផក.ប្រក ស្តីពីការអនុញ្ញាតអោយអ្នកស្រី ឡេង មួយ
ជនជាតិខ្មែរ បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ២៤ សេះ..... ៧៨

២៩.៥.១៩៩៥ – ប្រកាសលេខ ៤០១ ផក.ប្រក អនុញ្ញាតអោយអ្នកស្រី ហ៊ាង ស្រេង
ជនជាតិខ្មែរ បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ២៤ សេះ ៧៨

២៩.៥.១៩៩៥ – ប្រកាសលេខ ៤០២ ផក.ប្រក អនុញ្ញាតអោយលោក ឆឹង ស្រ៊ុន
ជនជាតិខ្មែរ បន្តដំណើរការរោងស៊ីនកិនស្រូវកំលាំង ២២ សេះ ៧៨

២៩.៥.១៩៩៥ – ប្រកាសលេខ ៤០៣ ផក.ប្រក អនុញ្ញាតអោយលោក ចាន់ ហ៊ុំ
ជនជាតិខ្មែរ បន្តដំណើរការរោងស៊ីនកិនស្រូវកំលាំង ១២០ សេះ ៧៨

២៩.៥.១៩៩៥ – ប្រកាសលេខ ៤០៤ ផក.ប្រក អនុញ្ញាតអោយលោក ជា ប្រាន
ជនជាតិខ្មែរ បន្តដំណើរការរោងស៊ីនកិនស្រូវកំលាំង ២៤ សេះ ៧៨

## ៣— ទីស្តីការរដ្ឋមន្ត្រី ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

### ប្រកាស

៣០.៥.១៩៩៥ – ប្រកាសលេខ ០០១ កបទ.សអ ស្តីពីការបែងចែកភារកិច្ចទទួលខុសត្រូវ
នៃមន្ត្រីថ្នាក់ដឹកនាំក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ៧៨

## ៤— ទីស្តីការរដ្ឋមន្ត្រី ក្រសួងពត៌មាន

### ប្រកាស

២៧.៥.១៩៩៥ – ប្រកាសលេខ ១១០/៩៥ ពម.ប្រក ស្តីពីការលុបឈ្មោះមន្ត្រីរាជការ ៧៩

២៩.៥.១៩៩៥ – ប្រកាសលេខ ១១១/៩៥ ពម.ប្រក ស្តីពីការផ្លាស់ប្តូរកន្លែងធ្វើការ
របស់មន្ត្រីរាជការ.................................................. ៧៩

៣១.៥.១៩៩៥ – ប្រកាសលេខ ១១២/៩៥ ពម.ប្រក ស្តីពីការតាំងស៊ុបក្នុងក្របខ័ណ្ឌ ៧៩

៣១.៥.១៩៩៥ – ប្រកាសលេខ ១១៣/៩៥ ស្តីពីការបញ្ចូលក្របខ័ណ្ឌពេញសិទ្ធិរបស់ក្រសួង ៧៩

## ៥— ទីស្តីការរដ្ឋមន្ត្រី ក្រសួងទេសចរណ៍

### ប្រកាស

១៥.៥.១៩៩៥ – ប្រកាសលេខ ០១៧ កទច.ប្រ ស្តីពីការតែងតាំងជាបណ្តោះអាសន្នចំពោះមន្ត្រីថ្នាក់ការិយាល័យ សំរាប់មន្ទីរទេសចរណ៍ក្រុងកែប............... ៧៩៥

## ៦— ទីស្តីការរដ្ឋមន្ត្រី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

### ប្រកាស

៣១.៥.១៩៩៥ – ប្រកាសលេខ ១១១ ប្រក.វ.វ.ស.ប ស្តីពីការបង្កើតគណៈមេប្រយោគប្រឡងយកសញ្ញាប័ត្រសិល្បៈ–ស្នាតកបត្រសិល្បៈឆ្នាំ ១៩៩៤.៩៥....... ៧៩៧

## ៧— ទីស្តីការរដ្ឋមន្ត្រី ក្រសួងអប់រំយុវជន និង កីឡា

### ប្រកាស

៣០.៥.១៩៩៥ – ប្រកាសលេខ ៦៤៣ អយក.ប្រក ស្តីពីការប្តូរឈ្មោះវិទ្យាល័យស្វាយតេ។ មកជាវិទ្យាល័យ នេតយ៉ង់ និងវិទ្យាល័យបាត់ដំបង មកជាវិទ្យាល័យព្រះមុនីវង្សនៅខេត្តបាត់ដំបង.................................................. ៧៩៩
៣១.៥.១៩៩៥ – ប្រកាសលេខ ៦៤៤ អយក.ប្រក ស្តីពីការរៀបចំប្រព្រឹត្តិទៅ នៃការប្រឡងសញ្ញាប័ត្រមធ្យមសិក្សាភូមិ ២.................................. ៨០០

## ៨— ទីស្តីការរដ្ឋមន្ត្រី ក្រសួងអភិវឌ្ឍន៍ជនបទ

### ប្រកាស

៣០.៥.១៩៩៥ – ប្រកសលេខ ១២២៧ អជប ស្តីពីការចាត់តាំងមន្ត្រីរាជការ ៨០៧

## ៩— ទីស្តីការក្រសួងធម្មការ និង សាសនា

### ប្រកាស

២៧.៥.១៩៩៥ – ប្រកាសលេខ ១០៦/៩៥ កធស.ប្រក ស្តីពីការទទួលស្គាល់មន្ត្រីរាជការក្នុងក្របខ័ណ្ឌមន្ទីរធម្មការ និង សាសនា ខេត្តតាកែវ.................. ៨០៨
៣០.៥.១៩៩៥ – ប្រកាសលេខ ១០៧/៩៥ កធស.ប្រក ស្តីពីការផ្ទេរមន្ត្រីរាជការក្នុងក្របខ័ណ្ឌក្រសួងធម្មការ និង សាសនា............................. ៨០៩

## ១០— ទីស្ដីការរដ្ឋមន្ត្រី យុវនិតិសម្បទា

### ប្រកាស

២៦.៥.១៩៩៥ – ប្រកាសលេខ ១២៣/៩៥ យន.ប្រក ស្ដីពីការតែងតាំងមន្ត្រីរាជការ របស់យុវនិតិសម្បទា.......................................... ៨១

២៦.៥.១៩៩៥ – ប្រកាសលេខ ១២៤/៩៥ យន.ប្រក ស្ដីពីការតែងតាំងមន្ត្រីរាជការ របស់យុវនិតិសម្បទា.......................................... ៨១

## ១១— រដ្ឋលេខាធិការដ្ឋានកិច្ចការនារី

### ប្រកាស

៣១.៥.១៩៩៥ – ប្រកាសលេខ ៥២២ រកន ស្ដីពីការផ្ទេរមន្ត្រីរាជការ ៨១

# I- ខុទ្ទកាល័យព្រះមហាក្សត្រ

## ១- ព្រះរាជក្រឹត្យ

**ព្រះរាជក្រឹត្យ នស/រកត/០៥៩៥/៤៦**

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុវរ្ម័ន**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ក្រឹត្យលេខ ២៨ ក្រ ចុះថ្ងៃទី ២០.៦.៨៨

××××

**ទ្រង់ត្រាស់បង្គាប់**

**មាត្រា ១ :** ត្រូវបន្ថយរយៈពេលរងទោសចំនួន ១២ ខែ ឱ្យទណ្ឌិតចំនួន ១៥ នាក់ដែលបាន ខិតខំអប់រំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសដូចមានរាយឈ្មោះខាងក្រោម ÷

១- ទណ្ឌិតឈ្មោះ [illegible] ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់២០ ឆ្នាំ តាមអំណាចសាលក្រមលេខ ២[illegible] ចុះថ្ងៃទី [illegible]-៨៧ របស់តុលាការខេត្តកំពង់ចាម

២- ទណ្ឌិតឈ្មោះ [illegible] ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២០ ឆ្នាំតាមអំណាចសាលក្រមលេខ [illegible] ចុះថ្ងៃទី [illegible]-៨៥ របស់តុលាការខេត្តកំពង់ចាម ។

៣ – ទណ្ឌិតឈ្មោះ **ម៉ក់ ឆាន** ហៅ **ម៉ក់ សារឿន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ២ ចុះថ្ងៃទី ៧-១១ ១៩៨៨ របស់តុលាការខេត្តកំពង់ឆ្នាំង ។

៤ – ទណ្ឌិតឈ្មោះ **រ៉ាឃ អ៊ុល** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ២ ចុះថ្ងៃទី ៧-១១ -៨៨ របស់តុលាការខេត្តកំពង់ឆ្នាំង ។

៥ – ទណ្ឌិតឈ្មោះ **ម៉ោញ តី** ហៅ **តាច** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនា គារ កំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ២៥ ចុះថ្ងៃទី ២០-១២-៩០ របស់តុលាការខេត្តកំពង់ឆ្នាំង ។

៦ – ទណ្ឌិតឈ្មោះ **ឈុំ ជួន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៦ ចុះថ្ងៃទី ១៦-៩-៨៩ របស់តុលាការខេត្តព្រៃវែង ។

៧– ទណ្ឌិតឈ្មោះ **ចាន់ សុខុម** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៧ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤ ចុះថ្ងៃទី ២៧-១០-៨៦ របស់តុលាការខេត្តព្រៃវែង ។

៨ – ទណ្ឌិតឈ្មោះ **សុក្រ ចន្ថា** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ៥ ចុះថ្ងៃទី ៨-៦-៨៨ របស់តុលាការខេត្តកោះកុង ។

៩ – ទណ្ឌិតឈ្មោះ **អោ គីន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣ ចុះថ្ងៃទី ៩-១០-៨៤ របស់តុលាការខេត្តកំពង់ចាម ។

១០– ទណ្ឌិតឈ្មោះ **ម៉ែន ចន្ថា** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៧ ឆ្នាំ តាមអំណាចសាលក្រមលេខ៣ ចុះថ្ងៃទី ២៧-១២-៨៦ របស់តុលាការខេត្តកំពង់ចាម ។

១១– ទណ្ឌិតឈ្មោះ **គោក សុខ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៤ ឆ្នាំ តាមអំណាចសាលក្រមលេខ ១ ចុះថ្ងៃទី ៧-១១-៨៨ របស់តុលាការខេត្តកំពង់ឆ្នាំង ។

១២– ទណ្ឌិតឈ្មោះ **ខឹម ខន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ១២ ចុះថ្ងៃទី១៧-៨-៩២ របស់តុលាការខេត្តព្រៃវែង ។

១៣– ទណ្ឌិតឈ្មោះ **និត សុវណ្ណ**ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤ ចុះថ្ងៃទី ៨-៦-៨៨ របស់តុលាការខេត្តកោះកុង ។

១៤– ទណ្ឌិតឈ្មោះ **សន វុំខ** ហៅ **សន ឡុខ** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាច សាលក្រមលេខ ១០ ចុះថ្ងៃទី ១៧-៨-៩២ របស់តុលាការខេត្តព្រៃវែង ។

**មាត្រា ២** : ត្រូវបន្ថយរយៈពេលរងទោសចំនួន ៦ ខែ ឱ្យទណ្ឌិតចំនួន ១ នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសដូចមានរាយនាមខាងក្រោមនេះ ÷

១ – ទណ្ឌិតឈ្មោះ **ខាន់ ឃឿន** ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៩ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៣ ចុះថ្ងៃទី ១-៤-៩៣ របស់តុលាការខេត្តព្រៃវែង ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ មានអនុភាពអនុវត្ត ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**មាត្រា ៤** : ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ ត្រូវអនុវត្តព្រះរាជក្រឹត្យនេះឱ្យបានសំរេចជាស្ថាពរ ។

ធ្វើនៅភ្នំពេញ , ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ១៩៩៥

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

# ព្រះរាជក្រឹត្យ នស/រកត/០៥៩៥/៤៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុវរ្ម័ន**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា .
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា .

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងលោកជំទាវ **សុខ ឃ្លឡឺពីរ** ជាទីប្រឹក្សាសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី១ ទទួលបន្ទុកកិច្ចការនារី មានឋានៈស្មើអនុរដ្ឋលេខាធិការ ។

**មាត្រា ២ :** នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី២ នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេច ព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ធ្វើនៅថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ១៩៩៥
**ព្រះហស្ថលេខា**
**នរោត្តម សីហនុ**

# II - ទីស្តីការគណៈរដ្ឋមន្ត្រី

## ១ - អនុក្រឹត្យ

*រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ១៩៩៥*

**អនុក្រឹត្យលេខ ៤៤ អនក្រ/បក**

**ស្តីពីការបង្កើតបញ្ជាការដ្ឋានកងរាជអាវុធហត្ថ**

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះបាទសម្តេចព្រះនរោត្តម **សីហនុ វរ្ម័ន** ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើតក្រសួងការពារជាតិ និងអគ្គសេនាធិការ នៃ កងទ័ពជាតិកម្ពុជា
- បានឃើញ អនុក្រឹត្យលេខ ៧៧ អនក្រ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ស្តីពីភារកិច្ច និង រចនាសម្ព័ន្ធទូទៅរបស់កងរាជអាវុធហត្ថ
- យោងតាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ .

**សំរេច**

**មាត្រា ១ :** ត្រូវបានបង្កើតបញ្ជាការដ្ឋានកងរាជអាវុធហត្ថ ខេត្ត **មណ្ឌលគិរី រតនៈគិរី ព្រះវិហារ** និង **ឧត្តរមានជ័យ** ស្ថិតនៅក្រោមការគ្រប់គ្រង និងបញ្ជាដឹកនាំផ្ទាល់របស់បញ្ជាការដ្ឋានកងរាជអាវុធហត្ថ នៃកងយោធពលខេមរភូមិន្ទ ។

**មាត្រា ២ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នាយអគ្គសេនាធិការ នៃ កងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ដែលចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះ ហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី១ | នាយករដ្ឋមន្ត្រីទី២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ១៩៩៥

**អនុក្រឹត្យលេខ ៤៥ អនក្រ.បក**

**ស្តីពីការបង្កើតអគ្គលេខាធិការដ្ឋានអធិការកិច្ច**

**របស់រាជរដ្ឋាភិបាល**

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា .
- បានឃើញអនុក្រឹត្យលេខ ៣០ អនក្រ ចុះថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការកំណត់ភារកិច្ច និង សមត្ថកិច្ចរបស់ទេសរដ្ឋមន្ត្រី ទទួលបន្ទុក អធិការកិច្ច
- បានឃើញ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រីដែល រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា បានអនុម័តកាលពីថ្ងៃទី ១៩ ខែកក្កដា

ឆ្នាំ ១៩៩៤ និងប្រកាសឱ្យប្រើតាមព្រះរាជក្រមរបស់ព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រីទទួលបន្ទុកអធិការកិច្ច .

## សំរេច

**មាត្រា ១ :** ត្រូវបានបង្កើត អគ្គលេខាធិការដ្ឋានអធិការកិច្ចរបស់រាជរដ្ឋាភិបាលមួយមានទីតាំងស្ថិតនៅ ទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីធ្វើជាសេនាធិការឱ្យទេសរដ្ឋមន្ត្រីទទួល បន្ទុកអធិការកិច្ច ។

**មាត្រា ២ :** អគ្គលេខាធិការដ្ឋានអធិការកិច្ច មានភារកិច្ច ÷

- គ្រប់គ្រងកិច្ចការរដ្ឋបាលដោយឡែក ក្នុងក្របខ័ណ្ឌការងារអធិការកិច្ចរាជរដ្ឋាភិបាល ដែលទទួលខុសត្រូវដោយទេសរដ្ឋមន្ត្រីទទួលបន្ទុកអធិការកិច្ច ។
- ក្តាប់សភាពការណ៍ សិក្សាស្រាវជ្រាវបញ្ញាគន្លឹះនានារបស់រាជរដ្ឋាភិបាល លើគ្រប់វិស័យ ដើម្បីជួយទេសរដ្ឋមន្ត្រីទទួលបន្ទុកអធិការកិច្ច កសាងផែនការកម្មវិធីការងារ និង ចាត់តាំងអនុវត្តរាល់ផែនការ និងកម្មវិធីទាំងនោះតាមនីតិវិធីអធិការកិច្ចសមស្របតាមកាលៈទេសៈជាក់ស្តែង ។
- ជំនួយការផ្ទាល់ជូនទេសរដ្ឋមន្ត្រីទទួលបន្ទុកអធិការកិច្ច ក្នុងការតាមដានត្រួតពិនិត្យអំពីការប្រព្រឹត្តិទៅ និងការធ្វើសកម្មភាពរបស់គ្រប់ក្រសួង ស្ថាប័នខេត្ត-ក្រុង នូវរាល់ការអនុវត្តន៍គោលការណ៍ គោលនយោបាយ អនុក្រឹត្យ សេចក្តីសំរេច សារាចរ សារាចរណែនាំ និងលិខិតបទដ្ឋាននានារបស់រាជរដ្ឋាភិបាល ។
- ទទួលពិនិត្យរឿងវិវាទរដ្ឋបាល ស្ថិតក្នុងសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល ដាក់ជូនទេសរដ្ឋមន្ត្រីទទួលបន្ទុកអធិការកិច្ចពិនិត្យសំរេច ដើម្បីចាត់ចែងអោយមាន ការដោះស្រាយត្រឹមត្រូវតាមនីតិវិធី និង ច្បាប់របស់រដ្ឋ ។
- បង្កលក្ខណៈងាយស្រួលដល់បេសកជន ឬប្រតិភូ ដែលចុះធ្វើអធិការកិច្ចតាំងពីពេលចាប់ផ្តើមរហូតដល់ពេលបញ្ចប់បេសកកម្ម ។

- ជួយទេសរដ្ឋមន្ត្រីទទួលបន្ទុកអធិការកិច្ច ដើម្បីធ្វើរបាយការណ៍សរុប អំពីសកម្មភាព និង លទ្ធផលការងារអធិការកិច្ចប្រចាំខែ ត្រីមាស ឆមាស ប្រចាំឆ្នាំ ជូនរាជរដ្ឋាភិបាល ។
- ទទួលភារកិច្ចផ្សេង ។ ទៀត ដែលទេសរដ្ឋមន្ត្រីទទួលបន្ទុកអធិការកិច្ចប្រគល់អោយ ។

**មាត្រា ៣ :** អគ្គលេខាធិការដ្ឋានអធិការកិច្ច មានសិទ្ធិ ÷

- កោះអញ្ជើញមន្ត្រី បុគ្គលិករាជការ ឬ ជនដែលពាក់ព័ន្ធ ដើម្បីសាកសួរពត៌មាន ផ្លាស់ប្តូរយោបល់ ផ្តល់ឯកសារ ឬចូលរួមសហការក្នុងសកម្មភាពធ្វើអធិការកិច្ច ។
- ក្រោយពេលធ្វើអធិការកិច្ចមួយលើក ។ មានសិទ្ធិធ្វើរបាយការណ៍តាមការធ្វើអធិការកិច្ចជាក់ស្តែង ដោយបញ្ជាក់អំពីការធ្វើត្រូវ ធ្វើខុស រួចសន្និដ្ឋាន និងលើកសំណូមពរជូនទេសរដ្ឋមន្ត្រីទទួលបន្ទុកអធិការកិច្ចពិនិត្យ ដើម្បីឯកភាពផ្ញើជូនរាជរដ្ឋាភិបាលសំរេច ។
- ចាត់ឱ្យចុះផ្សាយជាសាធារណៈនូវលទ្ធផល នៃ ការងារអធិការកិច្ច ដែលរាជរដ្ឋាភិបាលបានសំរេចហើយ ។

**មាត្រា ៤ :** អគ្គលេខាធិការដ្ឋានអធិការកិច្ច ដឹកនាំដោយអគ្គលេខាធិការមួយរូប អមដោយអគ្គលេខាធិការរងមួយចំនួនជាជំនួយការ និងមាននាយអធិការមួយចំនួនទៀតថ្នាក់ស្មើប្រធាននាយកដ្ឋានស្ថិតក្រោមឱវាទ ជួយធ្វើការងារជំនាញអធិការកិច្ច ។

**មាត្រា ៥ :** ក្របខ័ណ្ឌមន្ត្រីរាជការនៅអគ្គលេខាធិការដ្ឋានអធិការកិច្ច អាស្រ័យដោយទេសរដ្ឋមន្ត្រីទទួលបន្ទុកអធិការកិច្ចកំណត់ ដើម្បីលើកសំណើជូនរាជរដ្ឋាភិបាលពិនិត្យសំរេច ។

**មាត្រា ៦ :** ការចំណាយទាំងអស់សំរាប់សកម្មភាពរបស់អគ្គលេខាធិការដ្ឋានអធិការកិច្ចស្ថិតក្នុងថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា ៧ :** ការរៀបចំ និង ការប្រព្រឹត្តិទៅ នៃអគ្គលេខាធិការដ្ឋានអធិការកិច្ច ត្រូវកំណត់ដោយប្រកាសរបស់ទេសរដ្ឋមន្ត្រីទទួលបន្ទុកអធិការកិច្ច ។

**មាត្រា ៨** : ទេសរដ្ឋមន្ត្រីទទួលបន្ទុកអធិការកិច្ច សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន និងអភិបាលខេត្ត - ក្រុង ត្រូវទទួល អនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀង ៗ ខ្លួន ។

**មាត្រា ៩** : អនុក្រឹត្យនេះ មានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខានេះតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី១ | នាយករដ្ឋមន្ត្រីទី២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ១៩៩៥

**អនុក្រឹត្យលេខ ៦៣ អនក្រ.តត**

**ស្តីពីការតែងតាំងមន្ត្រីរាជការ**

**រាជរដ្ឋាភិបាល**

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា .
- បានឃើញ ច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ .
- តាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ .

## សម្រេច

**មាត្រា ១** : ត្រូវបានតែងតាំងមន្ត្រី បួន រូប :

- លោក **ហែម សារិន** ជាជំនួយការ ឯកឧត្តម **កឿង ម៉ារ** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ
- លោក **ស្វង ខាសនា** ជាជំនួយការ ឯកឧត្តម **កឿង ម៉ារ** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ
- លោក **ខ្មៅ សំឡុត** ជាជំនួយការ ឯកឧត្តម **កឿង ម៉ារ** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ
- លោក **សេ សំអុល** ជំនួយការ ឯកឧត្តម **កឿង ម៉ារ** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ

**មាត្រា ២** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងនិង ប្រធានស្ថាប័នពាក់ព័ន្ធ និង អស់លោកមានឈ្មោះក្នុងមាត្រា១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី១ | នាយករដ្ឋមន្ត្រីទី២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ១៩៩៥

**អនុក្រឹត្យលេខ ៦៤ អនក្រ.តត**

**ស្តីពីការលុបអនុក្រឹត្យលេខ ២៣ អនក្រ**

**និង អនុក្រឹត្យលេខ ៨៤ អនក្រ**

**រាជរដ្ឋាភិបាល**

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា .
- បានឃើញ ច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃ ទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ .
- តាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ .

**សំរេច**

**មាត្រា ១ :** ត្រូវបានចាត់ទុកជានិរាករណ៍អនុក្រឹត្យ លេខ ២៣ អនក្រ ចុះថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ១៩៩៥ និង អនុក្រឹត្យលេខ ៨៤ អនក្រ ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ១៩៩៤ ស្តីពីការតែងតាំងលោក **ស៊ុំឈាងខាន់** ជាអគ្គទីប្រឹក្សាអមស្ថានទូត នៃ ព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅព្រះរាជាណាចក្រថៃ និងជាភារៈធារីស្តីទី ប្រចាំសាធារណរដ្ឋសឹង្ហបុរី ដោយមូលហេតុលោក **ស៊ុំឈាងខាន់** ត្រូវបានផ្ទេរឱ្យមកទទួលភារកិច្ចថ្មីក្នុងប្រទេសវិញ ។

**មាត្រា ២ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងលោក **ស៊ុំឈាងខាន់** ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានិង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី១ | នាយករដ្ឋមន្ត្រីទី២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ១៩៩៥

**អនុក្រឹត្យលេខ ៦៥ អនក្រ.គត**

**ស្តីពីការជូនមេដាយស្ថាបនាជាតិ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយ ប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ. ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើត និង ប្រើប្រាស់មេដោយស្ថាបនាជាតិ និង ប័ណ្ណស្ថាបនាជាតិ
- តាមសំណើរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

**សំរេច**

**មាត្រា ១** : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិ ថ្នាក់លេខ ២ ជូនចំពោះ ក្រុមហ៊ុន និង សហ្បុរសជន ដែលបានឧបត្ថម្ភជាថវិកា និងសម្ភារៈក្នុងការស្តារប្រព័ន្ធធារាសាស្ត្រ និង ជួយសង្គ្រោះប្រជារាស្ត្រដែល រងគ្រោះដោយសារទឹកជំនន់ ដែលក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពល បានបែងចែកទៅខេត្តកណ្តាល , កំពង់ស្ពឺ, បាត់ដំបង់, និង ក្រុងព្រះ **សីហនុ** ដូចមានរាយនាមខាងក្រោមនេះ ÷

១–លោកឧកញ៉ា **ឡាយ ខឺ** គិតជាទឹកប្រាក់ចំនួន ៨.២០០ ដុល្លារអាមេរិក

២–លោក **នាយ អេខ** គិតជាទឹកប្រាក់ចំនួន ៧.៩៥០ ដុល្លារអាមេរិក

៣-ក្រុមហ៊ុន S.L Samling Co.Ltd គិតជាទឹកប្រាក់ចំនួន ៥.១៨០ ដុល្លារអាមេរិក

**មាត្រា ២ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ត្រូវ អនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អប្រសើរ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ១៩៩៥

**អនុក្រឹត្យលេខ ៦៦ អនក្រ.តត**

**ស្តីពីការជូនមេដាយស្ថាបនាជាតិ**

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយ ប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ.ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើត និង ប្រើប្រាស់មេដាយស្ថាបនាជាតិ និង បណ្ណស្ថាបនាជាតិ
- តាមសំណើរបស់មន្ទីរអប់រំយុវជន និង កីឡាខេត្ត ស្វាយរៀង

## សម្រេច

**មាត្រា ១ :** ត្រូវបានប្រគល់មេដាយស្ថាបនាជាតិ ជូនចំពោះសប្បុរសជនដែលមានសទ្ធាជ្រះថ្លា បានបរិច្ចាគ ទ្រព្យសម្បត្តិផ្ទាល់ខ្លួនចូលរួមជួយកសាងវិស័យអប់រំ យុវជន និង កីឡាខេត្តស្វាយរៀង ដូចមានរាយនាមខាងក្រោមនេះ ÷

ក–ជូនមេដាយស្ថាបនាជាតិថ្នាក់លេខ ២ ចំពោះឯកឧត្តម ឧត្តមសេនីយ៍ **តៅ សារ៉ាន់** និង លោក ជំទាវ **ឆឹង ឈេង** ដែលបានបរិច្ចាគប្រាក់ចំនួន ៨.៣៣៤,៣៧ ដុល្លារអាមេរិក ។

ខ–ជូនមេដាយស្ថាបនាជាតិ ថ្នាក់លេខ ៣ :

១–លោក **ម៉ី មួន** និង ភរិយា ទឹកប្រាក់ ២.១៥០ ដុល្លារអាមេរិក ។

២–លោក **សូ ចន្ថា** ទឹកប្រាក់១.២៥០ ដុល្លារអាមេរិក

៣–លោក **សូ គីមស៊ាន** ទឹកប្រាក់១.២៥០ ដុល្លារអាមេរិក

៤–លោក **ហ្វូ ម៉ុន** ទឹកប្រាក់១.២៥០ ដុល្លារអាមេរិក

៥–លោក **តៅ សេង** ទឹកប្រាក់១.២៥០ ដុល្លារអាមេរិក

៦–លោកស្រី **សូ ផល្លា** ទឹកប្រាក់១.២៥០ ដុល្លារអាមេរិក

**មាត្រា ២ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តស្វាយរៀង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ១៩៩៥

**អនុក្រឹត្យលេខ ៦៧ អនក្រ.តត**

**ស្ដីពីការតែងតាំងមន្ត្រី រាជការ**

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- តាមសំណើរបស់អាជ្ញាធរអាកាសចរស៊ីវិលកម្ពុជា

## សម្រេច

**មាត្រា ១** : តែងតាំង

- លោក **សុខ សំបូរ** ជាអគ្គនាយករង ទទួលបន្ទុកអាជ្ញាធរអាកាសយានដ្ឋាន
- លោក **ង៉ាន់ ចាន់ឡារ័ត្ន** ជាអគ្គនាយករង ទទួលបន្ទុកអាជ្ញាធរអាកាសចរស៊ីវិល

**មាត្រា ២** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ គ្រប់រដ្ឋលេខាធិការដ្ឋាន អាជ្ញាធរអាកាសចរស៊ីវិលកម្ពុជា និង សាមីខ្លួន ដែលមាន ចែងក្នុង មាត្រា ១ ត្រូវអនុវត្ត តាមអនុក្រឹត្យនេះ ចាប់ ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

## ២ - សារាចរណែនាំ

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ១៩៩៥

**សារាចរណែនាំលេខ ០២ សរណន.**

**ស្តីពីការអនុវត្តន៍ច្បាប់សហលក្ខន្តិកៈ**

**មន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា**

**យោង :** – រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

– ព្រះរាជក្រមលេខ ០៦ នស/៩៤ ចុះថ្ងៃទី ២៦ តុលា ឆ្នាំ ១៩៩៤

– ព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១-១១-១៩៩៤

ក្នុងគោលបំណងអនុលោមតាមច្បាប់ ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា អោយមានប្រសិទ្ធភាពរាជរដ្ឋាភិបាលសូមធ្វើការណែនាំដល់ក្រសួង រដ្ឋលេខាធិការដ្ឋាន និង ស្ថាប័នសាធារណៈពាក់ព័ន្ធទាំងអស់ ក្នុងព្រះរាជាណាចក្រកម្ពុជាទាំងមូល សូមអោយអនុវត្តច្បាប់ដូចមានចែងខាងលើនេះ អោយបានតឹងរ៉ឹងជាទីបំផុត ។

១–រដ្ឋមន្ត្រី និង រដ្ឋលេខាធិការដែលជាចៅក្រសួង ត្រូវកោះប្រជុំប្រធាននាយកដ្ឋានក្នុងស្ថាប័ន របស់ខ្លួនមកពន្យល់ណែនាំ និងតម្រូវអោយអនុវត្តតាមមាត្រាទាំងឡាយ នៃច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រី រាជការស៊ីវិលនេះអោយ បានសព្វគ្រប់ ។

២–បន្ទាប់មក ប្រធាននាយកដ្ឋានគ្រប់ ។ រូប ត្រូវពន្យល់ណែនាំដល់ បុគ្គលិករាជការទាំងឡាយ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួនរៀង ។ ខ្លួន ហើយត្រូវជំរុញអោយប្រកាន់យកជំហរ និង អនុវត្តតាមសេចក្តីណែនាំ ទាំងនោះជាកំហិត ។

រាជរដ្ឋាភិបាល សង្ឃឹមជឿជាក់យ៉ាងមាំថា បណ្តាក្រសួង រដ្ឋលេខាធិការដ្ឋាន និង ស្ថាប័ន ពាក់ព័ន្ធ និង ខិតខំយកចិត្តទុកដាក់អនុវត្តសារាចរណែនាំនេះ អោយមាន ប្រសិទ្ធភាពខ្ពស់ជាទីបំផុត ។

| | |
|---|---|
| នាយករដ្ឋមន្ត្រីទី ១ | នាយករដ្ឋមន្ត្រីទី ២ |
| ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

## ៣ - ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ១៩៩៥

**ប្រកាសលេខ ២៩ ប្រក.ចល**

**ស្តីពីការបញ្ចូលក្របខ័ណ្ឌមន្ត្រីរាជការ**

**សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា .
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០-៨-៩៤ .
- បានឃើញលិខិតលេខ ២៩៩ មស.ក្រខ ចុះថ្ងៃទី ១៣-៥-៩៥ របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ស្តីពីការឯកភាពអោយបញ្ចូលនិយោជិករោងពុម្ពសុខាភិបាល ចំនួន ២៩ នាក់ ក្នុងក្របខ័ណ្ឌទីស្តីការគណៈរដ្ឋមន្ត្រី .

**សំរេច**

**ប្រការ ១ :** និយោជិករោងពុម្ពសុខាភិបាលចំនួន ២៩ នាក់ដូចមានរាយនាមខាងក្រោម ដែលបច្ចុប្បន្នបំរើការងារនៅនាយកដ្ឋានរដ្ឋបាលផ្នែករាជកិច្ច ត្រូវបានបញ្ចូលក្របខ័ណ្ឌទីស្តីការគណៈរដ្ឋមន្ត្រី ចាប់ពីថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ ១៩៩៥ តទៅ ÷

១- លោក ពិន វិទ្ធី
២- លោក សោម សាញ់
៣- កញ្ញា ជ័យ ធានី
៤- លោកស្រី សួរ សារិន
៥- កញ្ញា ចាន់ លាភ
៦- លោក អោ ម៉ូវ

៧– លោក ស្វរ សុភាព
៨– លោក ញែម សុខុម
៩– លោក ចៅ សារី
១០– លោក ស៊ុយ ចន្ទមុនី
១១– លោក យ៉ង់ យឿន
១២– លោក អៀម ស៊ីណាំ
១៣– លោក អ៊ូច សារិន
១៤– លោក ធួន សារ៉ន
១៥– លោក ទិត ធី
១៦– លោក គង់ សារឿន
១៧– លោក អ៊ុំ ប៊ុន
១៨– លោក ភោគ សារ៉ាត
១៩– លោក ហៃ សំអុល
២០– លោក នៅ គុណ
២១– លោកស្រី មុំ សឿន
២២– កញ្ញា កុល មុន្នី
២៣– លោកស្រី ស្វ ផាន្នី
២៤– លោកស្រី ប្រេស សុផា
២៥– លោកស្រី សាន់ សុត្តារី
២៦– លោកស្រី គង់ ស៊ីណា
២៧– កញ្ញា គង់ បូផាណា
២៨– លោកស្រី ហ៊ឹម សារ៉ា
២៩– លោកស្រី អ៊ឹម ប៊ុក

**ប្រការ២** : លោកប្រធាននាយកដ្ឋានបុគ្គលិក នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានផ្គត់ផ្គង់ និងហិរញ្ញកិច្ច ព្រមទាំងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ។

សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា ហត្ថលេខា និង ត្រា

**សុខ អាន** **នូច កាន្ទុន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២៩ ខែ ០៥ ឆ្នាំ ១៩៩៥

**ប្រកាសលេខ ៣៣ ប្រ.ក**

**ស្តីពីការបង្កើត លេខាធិការដ្ឋានមេធាវី**

**របស់រាជរដ្ឋាភិបាល**

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា .
- បានឃើញ ព្រះរាជក្រមរបស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី .
- បានឃើញអនុក្រឹត្យលេខ ១៩៤ អនក្រ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៤ ស្តីពីការ តែងតាំងមេធាវីរបស់រាជរដ្ឋាភិបាលកម្ពុជា .

## សំរេច

**ប្រការ ១** : ត្រូវបង្កើតលេខាធិការដ្ឋានមេធាវី របស់រាជរដ្ឋាភិបាលមួយ មានទីតាំងស្ថិតនៅទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីធ្វើជាសេនាធិការ អោយមេធាវីរបស់រាជរដ្ឋាភិបាល ។

**ប្រការ ២** : លេខាធិការដ្ឋានមេធាវីរបស់រាជរដ្ឋាភិបាល មានភារកិច្ច ÷

- គ្រប់គ្រងកិច្ចការបណ្តឹងទាំងឡាយ ក្នុងក្របខ័ណ្ឌការងារមេធាវី ។
- ក្តាប់សភាពការណ៍ តាមដាន ស៊ើបអង្កេត សិក្សាស្រាវជ្រាវបញ្ហាគន្លឹះនានា និង ឯកសារលើវិស័យច្បាប់ ទៅគ្រប់ការប្តឹងផ្តល់របស់រាជរដ្ឋាភិបាល និង ការព្យួររាជរដ្ឋាភិបាល នៅចំពោះមុខតុលាការ ។
- ជំនួយការផ្ទាល់ជូនមេធាវីរបស់រាជរដ្ឋាភិបាលក្នុងការត្រួតពិនិត្យ អំពីសំណុំរឿងផ្សេងៗ ដែលពាក់ព័ន្ធនឹងបណ្តឹង ។
- ទទួលពិនិត្យរឿងវិវាទទាំងអស់ ដែលរាជរដ្ឋាភិបាលប្រគល់អោយ ។
- ទទួលភារកិច្ចផ្សេងៗទៀត ដែលមេធាវីរាជរដ្ឋាភិបាល ប្រគល់អោយ ។

**ប្រការ ៣** : លេខាធិការដ្ឋានមេធាវី ដឹកនាំដោយនាយលេខាធិការដ្ឋានមួយរូប អមដោយនាយលេខាធិការដ្ឋានរងជំនួយការ និងមានបុគ្គលិកជំនាញការមួយចំនួន សំរាប់បំរើការ ។

**ប្រការ ៤** : ក្របខ័ណ្ឌមន្ត្រីរាជការ នៅលេខាធិការដ្ឋានមេធាវី អាស្រ័យដោយមេធាវីរបស់រាជរដ្ឋាភិបាលកំណត់ ដើម្បីលើកសំណើជូន សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីពិនិត្យ និង សំរេច ។

**ប្រការ ៥** : ការចំណាយទាំងអស់ សំរាប់សកម្មភាពរបស់លេខាធិការដ្ឋានមេធាវី ស្ថិតក្នុងថវិការបស់ ទីស្តីការគណៈរដ្ឋមន្ត្រី ។

**ប្រការ ៦** : គ្រប់ប្រធាននាយកដ្ឋាន នៃ ទីស្តីការគណៈរដ្ឋមន្ត្រី និងមេធាវីរបស់រាជរដ្ឋាភិបាល ត្រូវទទួលអនុវត្តន៍តាមភារកិច្ចរៀង ៗ ខ្លួន ។

សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា ហត្ថលេខា និង ត្រា

**សុខ អាន** **ទ៉ែវ ស៊ីវុទ្ធា**

# III - ភាគរដ្ឋបាលក្រសួង

## ១ - ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ១៩៩៥

**ប្រកាសលេខ ១៣០ ប្រ.ក សហវ.ធរ**

**ស្ដីពី**

**ការតែងតាំងប្រធានគណកម្មាធិការជាតិទទួលការចូលនិយកម្ម សហគ្រាសសាធារណៈ**

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ច្បាប់ស្ដីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញ ព្រះរាជក្រឹត្យ នស.រកត. ១០៩៤,៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការ កែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញ ច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ០១ នស.ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញ ច្បាប់ហិរញ្ញវត្ថុ សំរាប់គ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ១០ នស. ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤

- បានឃើញសេចក្តីប្រកាសរបស់រាជរដ្ឋាភិបាល ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ ១៩៩៤ ស្តីពីឯកជនភាវូបនីយកម្ម សហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៣៨ អនក្រ. ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ១៩៩៥
- បានឃើញតំរូវការចាំបាច់របស់ក្រសួង

**សំរេច**

**ប្រការ ១** : តែងតាំងឯកឧត្តម **ឆាយ ថន** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាប្រធាន គណៈកម្មាធិការ ឯកជនភាវូបនីយកម្ម សហគ្រាសសាធារណៈ

**ប្រការ ២** : នាយខុទ្ទកាល័យ ប្រធានមន្ទីរអង្គភាពពាក់ព័ន្ធ ព្រមទាំងសាមីខ្លួន ត្រូវអនុវត្ត សេចក្តីប្រកាស នេះ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ហត្ថលេខា និង ត្រា

**គាត ឈន់**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ១៩៩៥

**ប្រកាសលេខ ១៣៣ ប្រក.សហវ.ថ**

**ស្តីអំពីការបង្វែរឥណទាន**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញច្បាប់ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពីការកែ សំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ ០១ នស.៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាស អោយប្រើច្បាប់ ស្ដីពីអំពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ១០ នស.៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្ដីអំពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥
- បានឃើញអនុក្រឹត្យរបស់រាជរដ្ឋាភិបាល លេខ ០៩ អនក្រ.ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ១៩៩៥ ស្ដីអំពីការបែងចែកឥណទានតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ១៩៩៥
- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លេខ ០០៤ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៥ ស្ដីពីការបែងចែកឥណទាន ផ្នែកក្នុងតាមជំពូក ប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ជូនបណ្ដាក្រសួងតាមឥណទានចែងក្នុង ច្បាប់ហិរញ្ញវត្ថុសំរាប់ ឆ្នាំ ១៩៩៥
- បានឃើញប្រកាសរបស់ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លេខ ០០៦ ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្ដីពីការណែនាំអនុវត្តថវិកា ឆ្នាំ ១៩៩៥
- តាមសំណើរបស់ ទីស្ដីការគណៈរដ្ឋមន្ត្រី លេខ ៤៣៥ ល.ស.ផហ.ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ១៩៩៥

**សំរេច**

**ប្រការ ១** : ត្រូវបានប្រតិបត្តិនៅក្នុងវង្វង់ថវិកា របស់ទីស្ដីការគណៈរដ្ឋមន្ត្រី សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ នូវការបង្វែរឥណទានដូចបានបញ្ជាក់ខាងក្រោមនេះ ÷

ឯកតា : ពាន់រៀល

| ជំពូក | ប្រការ | កថាខ័ណ្ឌ | វាក្យខ័ណ្ឌ | ចំណាត់ថ្នាក់ចំណាយ | ស្ថានភាពឥណទានដើមឆ្នាំ | ការកែប្រែ ឥណទាន កើន | ថយ | ស្ថានភាពទានថ្មី |
|---|---|---|---|---|---|---|---|---|
| | | | | ការបង្វែរពីជំពូក ១១ | | | 214.000 | |
| 11 | 01 | 12 | 01 | ការសិក្សា និង ពិសោធន៍ | 10.000 | - | 10.000 | 0 |
| 11 | 01 | 12 | 02 | សំភារៈមន្ទីរពិសោធន៍ និង សំភារៈបច្ចេកទេសតូចតាចប្រើប្រាស់ជាប្រចាំ | 10.000 | - | 10.000 | 0 |
| 11 | 01 | 12 | 03 | សិក្ខាសាលា ឬ កិច្ចប្រជុំ | 20.000 | - | 18.000 | 2.000 |
| 11 | 01 | 12 | 04 | កិច្ចសន្យា នៃ អ្នកជំនាញការ | 10.000 | - | 10.000 | 0 |
| 11 | 01 | 13 | | ការឃោសនា និង ផ្សព្វផ្សាយពត៌មានសាធារណៈ | 50.000 | - | 50.000 | 0 |
| 11 | 01 | 99 | | ចំណាយផ្សេងៗលើការប្រើប្រាស់ទ្រព្យសម្បត្តិនិងសេវាកម្មនានា | 116.000 | - | 116.000 | 0 |
| | | | | ផលប្រយោជន៍ជំពូក ១១ | | 214.000 | | |
| 11 | 01 | 14 | 04 | ចំណាយពិសេសរបស់នាយករដ្ឋមន្ត្រី | 2.800.000 | 214.000 | - | 3.014.000 |

**ប្រការ ២ :** ឯកឧត្តមសហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវទទួលបន្ទុកក្នុងការអនុវត្តន៍ប្រកាសនេះ ចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អនុរដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

**ឆាយ ថន**

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ១៩៩៥

**ប្រកាសលេខ ១៣៥ ប្រក.សហវ.ថ**

**ស្តីពីការបង្វែរឥណទាន**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**សម្រេច**

**ប្រការ ១ :** ត្រូវបានប្រតិបត្តិនៅក្នុងរង្វង់ថវិការបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ សំរាប់ការគ្រប់គ្រងថវិកា ឆ្នាំ ១៩៩៥ នូវការបង្វែរឥណទានដូចបានបញ្ជាក់ខាងក្រោមនេះ ÷

ឯកតា : ពាន់រៀល

| ជំពូក | ប្រការ | កថាខ័ណ្ឌ | វាក្យខ័ណ្ឌ | ចំណាត់ថ្នាក់ចំណាយ | ស្ថានភាពឥណទានដើមឆ្នាំ | ការកែប្រែ ឥណទាន | | ស្ថានភាពឥណទានថ្មី |
|---|---|---|---|---|---|---|---|---|
| | | | | | | កើន | ថយ | |
| | | | | ការបង្វែរពីជំពូក ១១ | | | 50.000 | |
| 11 | 01 | 12 | 04 | កិច្ចសន្យានៃអ្នកជំនាញការ | 116.100 | - | 50.000 | 66.100 |
| | | | | ផលប្រយោជន៍ជំពូក ១១ | | 50.000 | | |
| 11 | 01 | 01 | 03 | ទឹក | 900 | 900 | - | 1.800 |
| 11 | 01 | 02 | - | អចលនះវត្ថុ និង សំភារះ | 5.700 | 8.700 | - | 14.400 |
| 11 | 01 | 04 | - | ខោះពុម្ពនិងសំភារះការិយាល័យ | 22.800 | 25.000 | - | 47.800 |
| 11 | 01 | 05 | - | សៀវភៅមើល និង ឯកសារ | 400 | 400 | - | 800 |
| 11 | 01 | 07 | 01 | ការថែទាំ និង ដំណើរការ | 16.800 | 10.000 | - | 26.800 |
| 11 | 01 | 08 | 01 | សោហ៊ុយទទួលភ្ញៀវបរទេស | 6.000 | 5.000 | - | 11.000 |

**ប្រការ ២ :** ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ត្រូវទទួលបន្ទុកក្នុងការអនុវត្តន៍ប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អនុរដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

**ឆាយ ថន**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ១៩៩៥

**ប្រកាសលេខ ១៣៦ ប្រក.សហវ.ថ**

**ស្តីអំពីការបង្វែរឥណទាន**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**ប្រការ ១ :** ត្រូវបានប្រតិបត្តិនៅក្នុងរង្វង់ថវិកា របស់ក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ នូវការបង្វែរឥណទានដូចបានបញ្ជាក់ខាងក្រោមនេះ ÷

ឯកតា : ពាន់រៀល

| ជំពូក | ប្រការ | កថាខ័ណ្ឌ | វាក្យខ័ណ្ឌ | ចំណាត់ថ្នាក់ចំណាយ | ស្ថានភាពឥណទានដើមឆ្នាំ | ការកែប្រែ ឥណទាន | | ស្ថានភាពឥណទានថ្មី |
|---|---|---|---|---|---|---|---|---|
| | | | | | | កើន | ថយ | |
| | | | | ការបង្វែរពីជំពូក១១ | | | 42.700 | |
| 11 | 01 | 14 | 01 | ចោះពុម្ពឯកសារឡប់ការងារ | 50.700 | - | 40.700 | 10.000 |
| 11 | 01 | 99 | | ចំណាយផ្សេងៗលើការប្រើប្រាស់ទ្រព្យសម្បត្តិនិងសេវាកម្មនានា | 2.600 | - | 2.000 | 600 |
| | | | | ផលប្រយោជន៍ជំពូក ១១ | | 42.700 | | |
| 11 | 01 | 12 | 01 | ការសិក្សា និងពិសោធន៍ | - | 42.700 | - | 42.700 |

**ប្រការ ២ :** ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន ត្រូវទទួលបន្ទុកក្នុងការអនុវត្តន៍ ប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

**ស៊ុន ចាន់ថុល**

* * *

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ១៩៩៥

**ប្រកាសលេខ ១៤៣ ប្រក.សហវ.៩**

**ស្តីអំពីការបង្វែរឥណទាន**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**សម្រេច**

**ប្រការ ១ :** ត្រូវបានប្រតិបត្តិនៅក្នុងរង្វង់ថវិកា របស់ក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ នូវការបង្វែរឥណទានដូចបានបញ្ជាក់ខាងក្រោមនេះ ÷

ឯកតា : ពាន់រៀល

| ជំពូក | ប្រការ | កថាខ័ណ្ឌ | វាក្យខ័ណ្ឌ | ចំណាត់ថ្នាក់ចំណាយ | ស្ថានភាពឥណទានដើមឆ្នាំ | ការកែប្រែ ឥណទាន | | ស្ថានភាពឥណទានថ្មី |
|---|---|---|---|---|---|---|---|---|
| | | | | | | កើន | ថយ | |
| | | | | <u>ការបង្វែរពីជំពូក៣១</u> | <u>350.000,00</u> | | <u>94.000,00</u> | <u>256.000,00</u> |
| 31 | 01 | 02 | 05 | អាហារូបករណ៍ផ្សេងៗទៀត | 100.800,00 | - | 50.000,00 | 50.800,00 |
| 31 | 02 | 02 | - | ឧបត្ថម្ភមណ្ឌលកុមារកំព្រា | 155.700,00 | - | 44.000,00 | 111.700,00 |
| | | | | <u>ផលប្រយោជន៍ជំពូក៣២</u> | <u>30.000,00</u> | <u>94.000,00</u> | - | <u>124.000,00</u> |
| 32 | 01 | - | - | អង្គការសហប្រជាជាតិ | 30.000,00 | 94.000,00 | - | 124.000,00 |

**ប្រការ ២ :** ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន ត្រូវទទួលបន្ទុក ក្នុងការអនុវត្តន៍ ប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អនុរដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

**ឆាយ ថន**

* **

រាជធានីភ្នំពេញ,ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ១៩៩៥

**ប្រកាសលេខ ១៤៥ ប្រក សហវ.ថ**

**ស្តីអំពីការបង្វែរឥណទាន**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះន **រោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជ រដ្ឋាភិបាល
- បានឃើញ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រីដែល ប្រកាសអោយ ប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពី ការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ ០១ នស ៩៣. ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាស អោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ១០ នស ៩៤. ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ស្តីអំពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥

- បានឃើញអនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ ០៩ អនក្រ ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ១៩៩៥ ស្តីអំពីការបែងចែកឥណទានតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ១៩៩៥
- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លេខ ០០៤ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៥ ស្តីពីការបែងចែកឥណទាន ថ្លៃក្នុងតាមជំពូក ប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ជូនបណ្តាក្រសួងតាមឥណទានចែងក្នុង ច្បាប់ហិរញ្ញវត្ថុ សំរាប់ឆ្នាំ ១៩៩៥
- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុលេខ ០០៦ ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការណែនាំអនុវត្តថវិកា ឆ្នាំ ១៩៩៥
- តាមសំណើរបស់ក្រសួងពតិមាន លេខ ៣១៦ ពម. ចុះថ្ងៃទី ២១ ខែ មិនា ឆ្នាំ ១៩៩៥

**សំរេច**

**ប្រការ ១ :** ត្រូវបានប្រតិបត្តិនៅក្នុងរង្វង់ថវិកា របស់ក្រសួងពតិមាន សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥ នូវការបង្វែរឥណទានដូចបានបញ្ជាក់ខាងក្រោមនេះ :

ឯកត្តា : ពាន់រៀល

| ជំពូក | ប្រការ | កថាខ័ណ្ឌ | វាក្យខ័ណ្ឌ | ចំណាត់ថ្នាក់ចំណាយ | ស្ថានភាពឥណទានដើមឆ្នាំ | ការកែប្រែ ឥណទាន កើន | ការកែប្រែ ឥណទាន ថយ | ស្ថានភាពឥណទានថ្មី |
|---|---|---|---|---|---|---|---|---|
| | | | | <u>ការបង្វែរពីជំពូក ១១</u> | | | <u>9.249</u> | |
| 11 | 01 | 01 | 02 | ការរៀបចំនិងថែទាំ | 118.000 | - | 9.249 | 108.751 |
| | | | | <u>ផលប្រយោជន៍ជំពូក ១១</u> | | <u>9.249</u> | | |
| 11 | 01 | 02 | | អចលនវត្ថុនិងសំភារៈ | 9.000 | 9.249 | - | 18.249 |

**ប្រការ ២ :** ឯកឧត្តមរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ត្រូវទទួលបន្ទុកក្នុងការអនុវត្តន៍ប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អនុរដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

**គាយ ចន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ១៩៩៥

**ប្រកាសលេខ ១៤៦ ប្រក.សហវ.ទ**

**ស្ដីអំពីការបង្វែរឥណទាន**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី ដែលប្រកាសអោយ ប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្ដីពី ការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ ០១ នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែល ប្រកាសអោយប្រើច្បាប់ ស្ដីអំពីប្រព័ន្ធហិរញ្ញវត្ថុ

- បានឃើញព្រះរាជក្រមលេខ ១០ នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែល ប្រកាសអោយប្រើច្បាប់ស្តីអំពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥
- បានឃើញអនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ ០៩ អនក្រ ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ១៩៩៥ ស្តីអំពីការបែកចែកឥណទានតាមជំពូកនៃច្បាប់ ហិរញ្ញវត្ថុ ឆ្នាំ ១៩៩៥
- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុលេខ ០០៤ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៥ ស្តីពីការបែងចែកឥណទានផ្ទៃក្នុងតាមជំពូក ប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ជូនបណ្តាក្រសួងតាមឥណទានចែងក្នុងច្បាប់ ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៥
- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លេខ ០០៦ ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការណែនាំអនុវត្តថវិកា ឆ្នាំ ១៩៩៥
- តាមសំណើរបស់ក្រសួងអប់រំយុវជន និង កីឡា លេខ ៣៨២ អយក.ផក.ហវ ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៥

## សំរេច

**ប្រការ ១ :** ត្រូវបានប្រតិបត្តិនៅក្នុងរង្វង់ថវិកា របស់ក្រសួងអប់រំយុវជននិងកីឡាផ្នែកឧត្តមសិក្សាសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ នូវការបង្វែរឥណទានដូចបានបញ្ជាក់ខាងក្រោមនេះ :

ឯកតា : ពាន់រៀល

| ជំពូក | ប្រការ | កថាខ័ណ្ឌ | វាក្យខ័ណ្ឌ | ចំណាត់ថ្នាក់ចំណាយ | ស្ថានភាពឥណទានដើមឆ្នាំ | ការកែប្រែ ឥណទាន | | ស្ថានភាពឥណទានថ្មី |
|---|---|---|---|---|---|---|---|---|
| | | | | | | កើន | ថយ | |
| | | | | <u>ការបង្វែរពីជំពូក ១០</u> | | | <u>7.100</u> | |
| 10 | 02 | 03 | 03 | ប្រាក់រង្វាន់គរុកោសល្យ | 348.000 | - | 7.100 | 340.900 |
| | | | | <u>ផលប្រយោជន៍ជំពូក ១០</u> | | <u>7.100</u> | | |
| 10 | 03 | 01 | | បៀវត្សមូលដ្ឋាន | | 7.100 | - | 7.100 |

**ប្រការ ២** : ឯកឧត្តមរដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា ត្រូវទទួលបន្ទុកក្នុងការអនុវត្តន៍សេចក្តីប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ជ . រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អនុរដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

**ឆាយ ថន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ១៩៩៥

**ប្រកាសលេខ ១៤៧ ប្រក.សហវ.ថ**

**ស្តីអំពីការបង្វែរឥណទាន**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី ដែលប្រកាសអោយ ប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ នស រកត ១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពី ការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ ០១ នស ៩៣ ចុះថ្ងៃទី ២៨ ខែធ្នូឆ្នាំ១៩៩៣ ដែលប្រកាស អោយប្រើច្បាប់ ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ១០ នស ៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ស្តីអំពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥

- បានឃើញអនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ ០៩ អនក្រ ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ១៩៩៥ ស្តីអំពីការបែងចែកឥណទានតាមជំពូកនៃ ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ១៩៩៥
- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លេខ ០០៤ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៥
  ស្តីពីការបែងចែកឥណទានផ្ទៃក្នុងតាមជំពូក ប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ជូនបណ្តាក្រសួងតាមឥណទានចែងក្នុង ច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៥
- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុលេខ ០០៦ ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការណែនាំអនុវត្តថវិកាឆ្នាំ ១៩៩៥
- តាមសំណើរបស់ក្រសួងមហាផ្ទៃលេខ ០៤២ លស. ចុះថ្ងៃទី ០១ ខែ មីនា ឆ្នាំ ១៩៩៥ និង លេខ ៤៤០ លស ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ១៩៩៥

**សំរេច**

**ប្រការ ១** : ត្រូវបានប្រតិបត្តិនៅក្នុងរង្វង់ថវិកា ក្រសួងមហាផ្ទៃរដ្ឋបាល ទូទៅសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ នូវការបង្វែរឥណទានដូចបានបញ្ជាក់ខាងក្រោមនេះ ៖

ឯកតា : ពាន់រៀល

| ជំពូក | ប្រការ | កថាខ័ណ្ឌ | វាក្យខ័ណ្ឌ | ចំណាត់ថ្នាក់ចំណា | ស្ថានភាពឥណទានដើមឆ្នាំ | ការកែប្រែ ឥណទាន | | ស្ថានភាពឥណទានថ្មី |
|---|---|---|---|---|---|---|---|---|
| | | | | | | កើន | ថយ | |
| | | | | <u>ការបង្វែរពីជំពូក ១១</u> | | | <u>173.547,80</u> | |
| 11 | 02 | 02 | 01 | សោហ៊ុយដឹកជញ្ជូនក្រៅប្រទេស | 100.000,00 | | 16.793,40 | 83.206,60 |
| 11 | 01 | 11 | | ចំណាយសុវត្ថិភាពការងារ | 70.000,00 | | 38.140,70 | 31.859,30 |
| 11 | 01 | 99 | | ចំណាយផ្សេងៗលើការប្រើប្រាស់ទ្រព្យសម្បត្តិនិងសេវាកម្មនានា | 119.196,10 | | 118.613,70 | 582,40 |
| | | | | <u>ផលប្រយោជន៍ជំពូក ១១</u> | | <u>173.547,80</u> | | |
| 11 | 01 | 14 | 08 | ចំណាយទទួលភ្ញៀវ | 30.803,90 | 16.793,40 | | 47.597,30 |
| 11 | 01 | 01 | 02 | ការរៀបចំ និងថែទាំ | 100.000,00 | 156.754,40 | | 256.754,40 |

**ប្រការ ២** : ឯកឧត្តមសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវទទួលបន្ទុកក្នុងការអនុវត្តន៍ប្រកាសនេះ ចាប់ពីថ្ងៃចុះ ហត្ថលេខានេះតទៅ ។

ជ . រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អនុរដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

**ឆាយ ថន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ១៩៩៥

**ប្រកាសលេខ ១៤៨ ប្រក.សហវ.ម**

**ស្តីអំពីការបង្វែរកេណលនាន**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី ដែលប្រកាសអោយ ប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ នស រកត ១០៩៤/៩៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពី ការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញ ព្រះរាជក្រមលេខ ០១ នស ៩៣ ចុះថ្ងៃទី ២៨ ខែធ្នូឆ្នាំ១៩៩៣ ដែលប្រកាស អោយប្រើច្បាប់ ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ

- បានឃើញព្រះរាជក្រមលេខ១០ នស ៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ស្តីអំពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥
- បានឃើញអនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ ០៩ អនក្រ ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ១៩៩៥ ស្តីអំពីការបែងចែកឥណទានតាមជំពូកនៃ ច្បាប់ហិរញ្ញវត្ថុឆ្នាំ ១៩៩៥
- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លេខ ០០៤ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៥
ស្តីពីការបែងចែកឥណទានផ្ទៃក្នុងតាមជំពូក ប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ជូនបណ្តាក្រសួងតាមឥណទាន ចែងក្នុងច្បាប់ ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៥
- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុលេខ ០០៦ ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការណែនាំអនុវត្តថវិកាឆ្នាំ ១៩៩៥
- តាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុលេខ ០៩៦ សហវ. ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ១៩៩៥ និង លិខិតលេខ ៧៤៣ សហវ. ចុះថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ១៩៩៥

## សំរេច

**ប្រការ ១ :** ត្រូវបានប្រតិបត្តិនៅក្នុងវង្គថវិកា ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ នូវការបង្វែរឥណទានដូចបានបញ្ជាក់ខាងក្រោមនេះ :

ឯកតា : ពាន់រៀល

| ជំពូក | ប្រការ | កថាខ័ណ្ឌ | វាក្យខ័ណ្ឌ | ចំណាត់ថ្នាក់ចំណាយ | ស្ថានភាពឥណទានដើមឆ្នាំ | ការកែប្រែ ឥណទាន | | ស្ថានភាពឥណទានថ្មី |
|---|---|---|---|---|---|---|---|---|
| | | | | | | កើន | ថយ | |
| | | | | ការបង្វែរពីជំពូក ១១ | | | 150.000 | |
| 11 | 01 | 01 | 02 | ការរៀបចំ និង ថែទាំ | 500.000 | - | 150.000 | 350.000 |
| | | | | ផលប្រយោជន៍ជំពូក ១១ | | 150.000 | | |
| 11 | 01 | 02 | | ចលនវត្ថុ និង សំភារៈ | 150.000 | 90.000 | - | 240.000 |
| 11 | 02 | 01 | 03 | សោហ៊ុយស្នាក់នៅក្នុងប្រទេស | 70.000 | 60.000 | - | 130.000 |

**ប្រការ ២** : ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកក្នុងការអនុវត្តន៍ប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ជ . រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អនុរដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

**ឆាយ ថន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ១៩៩៥

**ប្រកាសលេខ ១៥៣ ប្រក.សហវ.៥**

**ស្តីអំពីការបង្វែរឥណទាន**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី ដែលប្រកាសអោយ ប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ នស រកត ១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពី ការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ ០១ នស ៩៣ ចុះថ្ងៃទី ២៨ ខែធ្នូឆ្នាំ១៩៩៣ ដែលប្រកាស អោយប្រើច្បាប់ ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ

- បានឃើញព្រះរាជក្រមលេខ១០ នស ៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ស្តីអំពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥
- បានឃើញអនុក្រឹត្យរបស់រាជរដ្ឋាភិបាលលេខ ០៩ អនក្រ ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ១៩៩៥ ស្តីអំពីការបែងចែកឥណទានតាមជំពូកនៃច្បាប់ហិរញ្ញវត្ថុឆ្នាំ ១៩៩៥
- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុលេខ ០០៤ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៥ ស្តីពីការបែងចែកឥណទានផ្ទៃក្នុងតាមជំពូក ប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ជូនបណ្តាក្រសួងតាមឥណទាន ចែងក្នុងច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៥
- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុលេខ ០០៦ ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការណែនាំអនុវត្តថវិកាឆ្នាំ ១៩៩៥
- តាមសំណើរបស់ក្រសួងផែនការ លេខ ១៧៨ ផ.ក ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ១៩៩៥

**សំរេច**

**ប្រការ ១** : ត្រូវបានប្រតិបត្តិនៅក្នុងរង្វង់ថវិកា របស់ក្រសួងផែនការ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ នូវការបង្វែរឥណទានដូចបានបញ្ជាក់ខាងក្រោមនេះ :

ឯកតា : ពាន់រៀល

| ជំពូក | ប្រការ | កថាខ័ណ្ឌ | វាក្យខ័ណ្ឌ | ចំណាត់ថ្នាក់ចំណាយ | ស្ថានភាពឥណទានដើមឆ្នាំ | ការកែប្រែ ឥណទាន | | ស្ថានភាពឥណទានថ្មី |
|---|---|---|---|---|---|---|---|---|
| | | | | | | កើន | ថយ | |
| | | | | ការបង្វែរពីជំពូក ៣១ | | | 4.600 | |
| 31 | 01 | 01 | 03 | គ្រោះថ្នាក់ក្នុងការងារ | 1.000 | - | 1.000 | - |
| 31 | 01 | 01 | 11 | ឧបត្ថម្ភដល់អ្នកសុំឈប់ការងារ | 3.200 | - | 2.300 | 900 |
| 31 | 01 | 02 | 03 | អាហារូបករណ៍សិស្សកំពុងសិក្សានានា | 4.000 | - | 1.300 | 2.700 |
| | | | | ផលប្រយោជន៍ជំពូក៣១ | | 4.600 | | |
| 31 | 01 | 01 | 02 | ឧបត្ថម្ភមន្ត្រីរាជការមានជំងឺ | 1.200 | 4.600 | - | 5.800 |

**ប្រការ ២ :** ឯកឧត្តមរដ្ឋមន្ត្រីក្រសួងផែនការ ត្រូវទទួលបន្ទុកក្នុងការអនុវត្តន៍ប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ជ . រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អនុរដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

**គាយ ចន**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ១៩៩៥

**ប្រកាសលេខ ១៥៥ ប្រក សហវ.៩**

**ស្តីអំពីការបង្វែរឥណទាន**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជ រដ្ឋាភិបាលកម្ពុជា .
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី ដែលប្រកាសអោយ ប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពី ការកែសំរួលសមាសភាពរាជរដ្ឋាភិបាល

- បានឃើញព្រះរាជក្រមលេខ ០១ នស ៩៣. ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាស អោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ១០ នស ៩៤. ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ស្តីអំពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៥
- បានឃើញអនុក្រឹត្យរបស់រាជរដ្ឋាភិបាល លេខ ០៩ អនក្រ ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ១៩៩៥ ស្តីអំពីការបែងចែកឥណទានតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ១៩៩៥
- បានឃើញប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ លេខ ០០៤ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៥ ស្តីពីការបែងចែកឥណទាន ផ្ទៃក្នុងតាមជំពូក ប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ជូនបណ្តាក្រសួងតាម ឥណទានចែងក្នុងច្បាប់ ហិរញ្ញវត្ថុ សំរាប់ឆ្នាំ ១៩៩៥
- បានឃើញ ប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុលេខ ០០៦ ចុះថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការណែនាំអនុវត្តថវិកា ឆ្នាំ ១៩៩៥
- តាមសំណើរបស់ក្រសួងអប់រំ យុវជន និងកីឡា លេខ ១២៥៦ អយក.ផក.ហវ ចុះថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ ១៩៩៥ លេខ ១២៥០ អយក.ផក.ហវ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ១៩៩៥ និងលេខ ១១១០ អយក.ផក.ហវ ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ១៩៩៥ .

**សំរេច**

**ប្រការ ១ :** ត្រូវបានប្រតិបត្តិនៅក្នុងរង្វង់ថវិកា របស់ក្រសួងអប់រំ យុវជន និង កីឡាសំរាប់ ការគ្រប់គ្រងផ្នែកយុវជន និង កីឡា ឆ្នាំ ១៩៩៥ នូវការបង្វែរឥណទានដូចបាន បញ្ជាក់ខាងក្រោមនេះ ÷

ឯកតា : ពាន់រៀល

| ជំពូក | ប្រការ | កថាខណ្ឌ | វាក្យខណ្ឌ | ចំណាត់ថ្នាក់ចំណាយ | ស្ថានភាពឥណទានដើមឆ្នាំ | ការកែប្រែ ឥណទាន | | ស្ថានភាពឥណទានថ្មី |
|---|---|---|---|---|---|---|---|---|
| | | | | | | កើន | ថយ | |
| | | | | ការបង្វែរពីជំពូក១១ | | | 82.500,00 | |
| 11 | 01 | 01 | 02 | ការរៀបចំថែទាំ | 64.500,00 | | 45.700,00 | 18.800,00 |
| 11 | 01 | 10 | | ចំណាយឯកសណ្ឋាន | 80.000,00 | | 13.600,00 | 66.400,00 |
| 11 | 01 | 11 | | ចំណាយសុវត្ថិភាពការងារ | 20.000,00 | | 5.000,00 | 15.000,00 |
| 11 | 01 | 14 | 04 | រង្វាន់ និងលើកសរសើរ | 80.000,00 | | 18.200,00 | 61.800,00 |
| | | | | ផលប្រយោជន៍ជំពូក ១១ | | 82.500,00 | | |
| 11 | 01 | 07 | 03 | សោហ៊ុយផ្លូវរថយន្ត | 3.000,00 | 2.600,00 | | 5.600,00 |
| 11 | 01 | 08 | 01 | សោហ៊ុយទទួលភ្ញៀវបរទេស | 40.000,.00 | 4.000,00 | | 44.000,00 |
| 11 | 01 | 09 | 04 | បុណ្យផ្សេង ៗ ទៀត | | 31.300,00 | | 31.300,00 |
| 11 | 01 | 14 | 01 | ការប្រឡងប្រជែងនិងការប្រឡង | | 40.000,00 | | 40.000,00 |
| 11 | 02 | 01 | 03 | សោហ៊ុយស្នាក់នៅ | 12.000,00 | 4.600,00 | | 16.600,00 |

**ប្រការ ២** : ឯកឧត្តមរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា ជាអ្នកទទួលបន្ទុកក្នុងការ អនុវត្តន៍ប្រកាសនេះចាប់ ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ជ – រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អនុរដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

**ឆាយ ថន**

* * *

## ២ - ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល

## ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ១៩៩៥

### ប្រកាសលេខ ៣៩៦ បល.ប្រក

### ស្តីពីការតែងតាំង និង ផ្ទេរភារកិច្ចមន្ត្រីរាជការ

### រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** **វរ្ម័ន** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែង តាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញប្រកាសលេខ ១២៩២ បល.ប្រក ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ១៩៩៤ ស្តីពីការតែងតាំងលោក **កែវ សម្បត្តិ** ជាអនុប្រធាននាយកដ្ឋានបុគ្គលិក
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ របស់ រាជរដ្ឋាភិបាលបាលកម្ពុជា ស្តីពីការផ្ទេរលោក **ខា គង់** ប្រធានមន្ទីរក្រសួង ឧស្សាហកម្មរ៉ែ និង ថាមពល អោយទៅបំរើការងារនៅ រដ្ឋលេខាធិការដ្ឋាន ទំនាក់ទំនងជាមួយសភា
- ពិនិត្យសំណូមពរការងារចាំបាច់របស់ក្រសួង

### សំរេច

**ប្រការ ១ :** ចាត់តាំងលោក **រស់ សារិន** បច្ចុប្បន្នអនុប្រធាន មន្ទីរនៃទីស្តីការ អោយទទួលបន្ទុកភ្ជាប់រួមបណ្តោះអាសន្ន ដើម្បីដោះស្រាយការងារក្នុងអង្គភាពជំនួសលោក **ខា គង់** ដែលត្រូវទៅ ទទួលភារកិច្ចនៅអង្គភាពថ្មី ។

**ប្រការ ២** : ផ្ទេរភារកិច្ចលោក **កែវ សម្បត្តិ** ពីអនុប្រធាននាយកដ្ឋានបុគ្គលិកអោយទៅធ្វើជាអនុប្រធានមន្ទីរនៃទីស្តីការ ។

**ប្រការ ៣** : លោកនាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញកិច្ច និង សាមីជនដូចមានចែងក្នុងប្រការ ១ និងប្រការ ២ មានភារកិច្ចអនុវត្តក្នុង ក្របខ័ណ្ឌសមត្ថកិច្ចរៀង ៗ ខ្លួនតាមប្រកាសនេះ ។

**ប្រការ ៤** : ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីកាលបរិច្ឆេទចុះហត្ថលេខាតទៅ ។

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ១៩៩៥

**ប្រកាសលេខ ៣៩៧ មឈ.ប្រក**

**ស្តីពីការតែងតាំងមន្ត្រីរាជការ**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល**

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- ពិនិត្យសំណូមពរការចាំបាច់របស់ក្រសួង

**សម្រេច**

**ប្រការ ១** : តែងតាំងលោក **ឆា ចណ្ណធួន** ជាលេខាធិការផ្ទាល់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល ។

**ប្រការ ២** : លោកនាយកខុទ្ទកាល័យ លោកប្រធានមន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញកិច្ច និងលោក **ឆា ចណ្ណធួន** មានភារកិច្ចអនុវត្តក្នុងក្របខ័ណ្ឌ សមត្ថកិច្ចរៀង ៗ ខ្លួនតាមប្រកាសនេះ ។

**ប្រការ ៣ :** ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីកាលបរិច្ឆេទចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ពូ សុធីរៈ**

* * *

**ប្រកាសលេខ ៤០០ ផក.ប្រក**

**ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ១៩៩៥**

**ប្រការ ១ :** អនុញ្ញាតអោយអ្នកស្រី **ឡេង មួយ** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ៣២៩២៣៩ ក.ណ ចុះថ្ងៃទី ១០_៨_១៩៩០ អាស័យដ្ឋាន បច្ចុប្បន្ន ភូមិពោធិរាម្នា ឃុំព្រែកស្ដី ស្រុកកោះធំ ខេត្តកណ្ដាល បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ២៤ សេះ នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

**ប្រការ ២ :** អ្នកស្រី **ឡេង មួយ** ត្រូវបន្តដំណើរការផលិតកម្មអាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិច បំផុត ៦៥ ភាគរយ ។

**ប្រការ ៣ :** ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋានប្រកាសនេះ នឹងត្រូវដកហូត វិញដោយគ្មានសំណង ឡើយ ។

* * *

**ប្រកាសលេខ ៤០១ ឧក.ប្រក**
**ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ១៩៩៥**

**ប្រការ ១ :** អនុញ្ញាតអោយអ្នកស្រី **ម៉ែង ស្រេង** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ២២៨៧៣០ក.ណ ចុះថ្ងៃទី ១២_០១_១៩៨៩ អាស័យដ្ឋានបច្ចុប្បន្នភូមិព្រែកតាហ៊ីង ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្តាល បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ២៤ សេះ នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

**ប្រការ ២ :** អ្នកស្រី **ម៉ែង ស្រេង** ត្រូវបន្តដំណើរការផលិតកម្មអាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុងប្លង់ ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

**ប្រការ ៣ :** ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្ក អោយមានការប៉ះពាល់ដល់បរិដ្ឋានប្រកាសនេះ នឹងត្រូវដកហូតវិញដោយគ្មានសំណង ឡើយ ។

* * *

**ប្រកាសលេខ ៤០២ ឧក.ប្រក**
**ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ១៩៩៥**

**ប្រការ ១ :** អនុញ្ញាតអោយលោក **ឆ៊ិន ស៊្រុន** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ០១៦៥៨៦ ក.ណ ចុះថ្ងៃទី ១៥_០១_១៩៨៦ អាស័យដ្ឋានបច្ចុប្បន្នភូមិលេខ ៧ ឃុំសំពៅពូន ស្រុកកោះធំ ខេត្តកណ្តាល បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ២២ សេះ នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

**ប្រការ ២ :** លោក **ឆ៊ិន ស៊្រុន** ត្រូវបន្តដំណើរការផលិតកម្មអាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុងប្លង់ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

**ប្រការ ៣ :** ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋានប្រកាសនេះ នឹងត្រូវដកហូតវិញដោយគ្មានសំណង ឡើយ ។

* * *

**ប្រកាសលេខ ៤០៣ ឧក. ប្រក**

**ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ១៩៩៥**

**ប្រការ ១ :** អនុញ្ញាតអោយលោក **ចាន់ ហុី** ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៧៣៨៣៤ ព.ស ចុះថ្ងៃទី ០៨-១២-១៩៨៩ អាស័យដ្ឋានបច្ចុប្បន្ន ក្រុមទី ៤ ភូមិអូរតាប៉ោង ឃុំអូរតាប៉ោង ស្រុកបាកាន ខេត្តពោធិសាត់ បន្តដំណើរការរោង ម៉ាស៊ីនកិនស្រូវកំលាំង ១២០ សេះ នៅក្នុងទីតាំងក្រុមទី ៦ ភូមិអូរតាប៉ោង ឃុំអូរតាប៉ោង ស្រុកបាកាន ខេត្តពោធិសាត់ ។

**ប្រការ ២ :** លោក **ចាន់ ហុី** បន្តដំណើរការផលិតកម្មអាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុងប្លង់ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

**ប្រការ ៣ :** ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្ក អោយមានការប៉ះពាល់ដល់បរិដ្ឋានប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណង ឡើយ ។

* * *

**ប្រកាសលេខ ៤០៤ ផក.ប្រក**
**ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ១៩៩៥**

**ប្រការ ១ :** អនុញ្ញាតអោយលោក ខា ឆ្វាន ជនជាតិខ្មែរ សញ្ជាតិកម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ៣៨៤៧៣៤ ក.ណ ចុះថ្ងៃទី ០៣-៧-១៩៩២ អាស័យដ្ឋានបច្ចុប្បន្ន ភូមិព្រែកតាដួង ឃុំ ព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្តាល បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ២៤ សេះ នៅក្នុងទីតាំងដូចអាស័យដ្ឋានខាងលើ ។

**ប្រការ ២ :** លោក ខា ឆ្វាន ត្រូវបន្តដំណើរការផលិតកម្មអាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុងប្លង់ដោយធានានូវទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

**ប្រការ ៣ :** ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់ពេលនេះម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តិល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិដ្ឋាន ប្រកាសនេះនឹង ត្រូវដកហូតវិញដោយគ្មានសំណង ឡើយ ។

រដ្ឋមន្ត្រី
ហត្ថលេខា និង ត្រា
ពូ សុធីរៈ

* * *

## ៣ - នីស្តីការរដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

**ប្រកាស**

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ១៩៩៥

**ប្រកាសលេខ ០០១ កបអ.សអ**

**ស្តីពីការបែងចែកភារកិច្ចទទួលខុសត្រូវនៃមន្ត្រីថ្នាក់ដឹកនាំ**

**ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

**រដ្ឋមន្ត្រីការបរទេស និង សហប្រតិបត្តិការអន្តរជាតិ**

- យោងតាមរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- យោងតាមច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ កក្កដា១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រឹត្យលេខ ០២ ន.ស ចុះថ្ងៃទី ២០ កក្កដា ១៩៩៤ ។
- យោងតាមព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល ។
- យោងតាមព្រះរាជក្រឹត្យចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការតែងតាំងឯកឧត្តម អ៊ឹង ហួត ជារដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- យោងតាមសំណើរៀបចំរចនាសម្ព័ន្ធ នៃ ក្រសួងការបរទេស និង សហប្រតិ - បត្តិការអន្តរជាតិដែលរាជរដ្ឋាភិបាលបានសំរេច ឯកភាពតាមលិខិត សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណរដ្ឋមន្ត្រីលេខ ៧២៤ សជណ.ផក ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ១៩៩៣ ។

**សំរេច**

**I. ឋានានុក្រម**

**ប្រការ ១ :** ថ្នាក់ដឹកនាំនៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មានសមាសភាពតាមលំដាប់ឋានានុក្រមដូចតទៅ :

១– រដ្ឋមន្ត្រី

២– រដ្ឋលេខាធិការ

៣– អនុរដ្ឋលេខាធិការ

៤– អគ្គលេខាធិការ

**ប្រការ ២ :** រដ្ឋមន្ត្រីជាប្រធានស្ថាប័ន មានសិទ្ធិ ភារកិច្ច និងសមត្ថកិច្ច :

១–បំពេញនិងអនុវត្តគោលការណ៍នយោបាយ ការបរទេស នៃ រាជរដ្ឋាភិបាលកម្ពុជា និងរៀបចំមាតិនយោបាយការបរទេសជូនរាជរដ្ឋាភិបាលកម្ពុជា ។

២–ដឹកនាំការងារស្ថាប័នទាំងមូល និងគ្រប់គ្រងបុគ្គលិក មន្ត្រីការទូត មន្ត្រីរាជការ ដែលជាភ្នាក់ងារ រដ្ឋបាលកណ្តាល និងរដ្ឋបាលមូលដ្ឋាន នៃ ក្រសួងព្រមទាំងស្ថានទូត ស្ថានកុងស៊ុលនិងស្ថានបេសកកម្ម អចិន្ត្រៃយ៍នៃព្រះរាជាណាចក្រកម្ពុជា នានាប្រចាំអង្គការសហប្រជាជាតិ អង្គការអន្តរជាតិនៅបរទេសដែលឋិតនៅក្រោមឱវាទក្រសួង ។

៣–លើកសំណើតែងតាំង ផ្លាស់ប្តូរ បញ្ចប់ភារកិច្ចមន្ត្រីការទូត មន្ត្រីរាជការ ក្រោមឱវាទតាមបែបបទនិងនីតិវិធី ជាធរមានដោយអនុក្រឹត្យចាប់តាំងពីថ្នាក់ប្រធាននាយកដ្ឋាន និងថ្នាក់ប្រហាក់ប្រហែលឡើងទៅ ។

៤–តែងតាំង ផ្លាស់ប្តូរ បញ្ចប់ភារកិច្ច មន្ត្រីការទូត មន្ត្រីរាជការ ក្រោមឱវាទដោយប្រកាសចាប់ពីថ្នាក់ក្រោមនាយកដ្ឋាន និង ថ្នាក់ប្រហាក់ប្រហែលតាមបែបបទនិងនីតិវិធីជាធរមាន ។

៥–ចេញប្រកាសនិងសារាចរ ជាអត្ថបទសំរាប់បំពេញកិច្ចការ និងធ្វើការណែនាំ ។ ប្រកាសឬសារាចររបស់ស្ថាប័នមិនអាចចែងពីការអ្វីដែលមិនចូលក្នុងរង្វង់ក្របខ័ណ្ឌសមត្ថកិច្ចស្ថាប័នឡើយ ហើយក៏ពុំអាចមានទំនាស់ជាមួយលិខិតបទដ្ឋាននានា ដូចជាអនុក្រឹត្យ ឬសារាចររបស់រាជរដ្ឋាភិបាលដែរ ។

**ប្រការ ៣ :** រដ្ឋលេខាធិការ ជាអនុប្រធានស្ថាប័ន មានសិទ្ធិ ភារកិច្ច និង សមត្ថកិច្ចជួយដឹកនាំ សំរេចនិងអនុវត្តតាមភារកិច្ចដែលរដ្ឋមន្ត្រីប្រគល់ជូន ។

**ប្រការ ៤ :** រាល់បញ្ហាធំៗ រដ្ឋមន្ត្រីប្រធានស្ថាប័នមានភារកិច្ចត្រូវពិគ្រោះជាមួយរដ្ឋលេខាធិការ អនុប្រធានស្ថាប័ន មុននិងធ្វើសេចក្តីសំរេចជាស្ថាពរ ។

**ប្រការ ៥ :** អនុរដ្ឋលេខាធិការ មានសិទ្ធិភារកិច្ចជួយដឹកនាំកិច្ចការក្នុងក្រសួង តាមការប្រគល់ភារកិច្ច នៃរដ្ឋមន្ត្រីប្រធានស្ថាប័ន ។

**ប្រការ ៦** : អគ្គលេខាធិការ ជាភ្នាក់ងាររដ្ឋបាលអចិន្ត្រៃយ៍ជាន់ខ្ពស់ ទទួលខុសត្រូវនូវនិរន្តភាពផ្នែករដ្ឋបាលទូទៅរបស់ក្រសួង ។ អគ្គលេខាធិការមានភារកិច្ចទទួលខុសត្រូវគ្រប់គ្រងការងាររដ្ឋបាលទូទៅអោយដំណើរការប្រកបដោយប្រសិទ្ធភាព និងស្មេរភាពក្រោមការណែនាំរបស់ប្រធាន និង អនុប្រធានស្ថាប័ន ។

**ប្រការ ៧** : ទីប្រឹក្សារបស់រដ្ឋមន្ត្រី ជាអ្នកជំនាញ និង ជំនួយការផ្ទាល់របស់រដ្ឋមន្ត្រី ប្រធានស្ថាប័ន មានសិទ្ធិ តួនាទី និងអនុវត្តភារកិច្ចដែលរដ្ឋមន្ត្រី ប្រធានតំរូវជូន ផ្ទាល់ ឬតាមរយៈរដ្ឋលេខាធិកា អនុប្រធានស្ថាប័ន ។

**ប្រការ ៨** : នាយកខុទ្ទកាល័យ ជាភ្នាក់ងាររដ្ឋបាលជាន់ខ្ពស់ជាសហការីផ្ទាល់ ប្រកបកិច្ចការក្រោមនិវាទផ្ទាល់របស់រដ្ឋមន្ត្រីប្រធានស្ថាប័ន មានសិទ្ធិនិង តួនាទីអនុវត្តតាមភារកិច្ចដែលរដ្ឋមន្ត្រីប្រគល់ជូន ។

## II- ការបែងចែកភារកិច្ច និង សិទ្ធិសំរេច:

**ប្រការ ៩** : រដ្ឋលេខាធិការ ជាអនុប្រធានស្ថាប័ន និងសមាជិកនៃរាជរដ្ឋាភិបាលអមរដ្ឋមន្ត្រី មានសិទ្ធិ តួនាទីទទួលខុសត្រូវជួយដឹកនាំ និងសំរេចលើកិច្ចការទូទៅរបស់រដ្ឋមន្ត្រី និងក្នុងក្របខ័ណ្ឌភារកិច្ចដែលរដ្ឋមន្ត្រីប្រគល់អោយ ។

**ប្រការ១០** : អនុរដ្ឋលេខាធិការត្រូវមានសិទ្ធិ និង តួនាទីទទួលខុសត្រូវចំពោះមុខប្រធាន និង អនុប្រធានស្ថាប័នក្នុងភារកិច្ចពិសេសដូចតទៅ ដែលរដ្ឋមន្ត្រីប្រគល់ជូនផ្ទាល់តាមរយៈរដ្ឋលេខាធិការ ÷

១- អនុរដ្ឋលេខាធិការមួយរូបទទួលបន្ទុក : នាយកដ្ឋានអាស៊ី នាយកដ្ឋានអាស៊ាន នាយកដ្ឋានសារពត៌មាន នាយកដ្ឋានច្បាប់ នាយកដ្ឋានអាមេរិក នាយកដ្ឋានអឺរ៉ុប នាយកដ្ឋានអាហ្វ្រិក និង មជ្ឈិមបូព៌ា ។

២-អនុរដ្ឋលេខាធិការមួយរូបទៀតទទួលបន្ទុក : នាយកដ្ឋានសហប្រតិបត្តិការ នាយកដ្ឋានអង្គការសហប្រជាជាតិ អង្គការអន្តរជាតិ និង អង្គការមិនមែនរដ្ឋាភិបាល ។

**ប្រការ១១** : អគ្គលេខាធិការទទួលបន្ទុកនាយកដ្ឋានរដ្ឋបាលទូទៅ និងនាយកដ្ឋានពិធីការមានសិទ្ធិ តួនាទីភារកិច្ចទទួលខុសត្រូវជួយពិនិត្យដឹកនាំ ផ្នែកការងាររដ្ឋបាលទូទៅ និង

ពិធីការចំពោះរដ្ឋមន្ត្រី ប្រធានស្ថាប័នផ្ទាល់ ឬតាមរយៈរដ្ឋលេខាធិការ អនុប្រធានស្ថាប័ន ។

អគ្គលេខាធិការ អាចផ្តល់មតិលើសំណុំរឿងការងាររបស់នាយកដ្ឋាននានា ដែលនៅ ក្រោមឱវាទ និង បន្ទុកផ្ទាល់ នៃ អនុរដ្ឋលេខាធិការទាំងពីររូប ។

អគ្គលេខាធិការ មានភារកិច្ចត្រូវធ្វើរបាយការណ៍សរុបការងារ ប្រចាំសប្តាហ៍ ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំរបស់ក្រសួងទាំងអស់ ដាក់ជូនប្រធាន ស្ថាប័នពិនិត្យ និងអនុម័ត ។

**ប្រការ១២** :កិច្ចការងារដែលអនុរដ្ឋលេខាធិការ និង អគ្គលេខាធិការអាចសំរេចបាន និង កំណត់ លំអិតជាក្រោយដោយរដ្ឋមន្ត្រីប្រធានស្ថាប័ន ( **Annexe** ) ។

## III- ចរន្តនៃលិខិត និង សំណុំរឿង

**ប្រការ១៣** : ក–រាល់សំបុត្រស្នាម ឬសំណុំរឿងដែលទទួលមកពីក្នុង ឬក្រៅប្រទេសត្រូវចូលតាម ការិយាល័យរបៀបនៃនាយកដ្ឋានរដ្ឋបាលទូទៅ ។

ខ–ការិយាល័យរបៀបត្រូវវាយត្រាចុះបញ្ជីចុះលេខថ្ងៃខែហើយបែងចែកអោយបានច្បាស់លាស់តាមលិខិតរដ្ឋបាល លិខិតផ្ទាល់ខ្លួន លិខិតប្រញាប់ លិខិតសម្ងាត់ ។ ល ។ រួចហើយចាត់បញ្ជូនជាបន្ទាន់ទៅតាមករណីនិមួយ ៗ និងតាមនាយកដ្ឋានសាមីនានាតាមសមត្ថកិច្ច ។

គ–នាយកដ្ឋាននានាពិនិត្យស្រាវជ្រាវលិខិតទាំងនោះ រួចកសាងសំណុំរឿង ធ្វើជាកំណត់បង្ហាញដាក់ជូនអគ្គលេខាធិការ ។

ឃ–អគ្គលេខាធិការ ត្រូវពិនិត្យហើយផ្តល់មតិលើសំណុំរឿងទាំងនោះ កែលំអ (បើយល់ថាចាំបាច់) ហើយដាក់ជូនទៅអនុរដ្ឋលេខាធិការទាំងពីររូបតាមភារកិច្ចរៀង ៗ ខ្លួន ។

ង–អនុរដ្ឋលេខាធិការ ពិនិត្យមានមតិកែលំអមុននឹងបញ្ជូនបន្តជូន រដ្ឋលេខាធិការ ។

ច–រដ្ឋលេខាធិការ ពិនិត្យមានមតិកែលំអចុងក្រោយមុននឹងដាក់ជូនរដ្ឋមន្ត្រីពិនិត្យ សំរេច ឬ ចុះហត្ថលេខា ។

ចំពោះសំណុំរឿងផ្នែកការងាររដ្ឋបាលទូទៅ អគ្គលេខាធិការពិនិត្យសំរេច ឬ ផ្តល់មតិជូន រដ្ឋមន្ត្រី ប្រធានស្ថាប័នផ្ទាល់ ឬ តាមរយៈរដ្ឋលេខាធិការតាមភារកិច្ចដែលរដ្ឋមន្ត្រីប្រគល់ជូន ។

ឆ–ពង្រាងលិខិតដែលបានកែលំអចុងក្រោយហើយត្រូវបញ្ជូនទៅនាយកដ្ឋានសាមីវិញដើម្បីវាយអោយស្អាតរួចដាក់ជូនថ្នាក់ដែលត្រូវចុះហត្ថលេខាដោយផ្ទាល់ ដោយមិនចាំបាច់ឆ្លងលំដាប់ថ្នាក់ដូចមុនទៀតទេ ។

ជ–នាយកខុទ្ទកាល័យ ពិនិត្យផ្ទៀងផ្ទាត់ត្រឹមត្រូវទាំងខ្លឹមសារ ទាំងរូបភាព ទើបដាក់ជូន រដ្ឋមន្ត្រី ចុះហត្ថលេខា ។

**ប្រការ១៤** : រាល់សំណុំរឿងដែលត្រូវដាក់ជូនរដ្ឋមន្ត្រី ត្រូវបញ្ជូនតាមរយៈនាយកខុទ្ទកាល័យ ដោយមានការផ្តល់មតិពីរដ្ឋលេខាធិការ ។

**ប្រការ១៥** : រាល់លិខិតសំណុំរឿងដែលចេញពីរដ្ឋមន្ត្រីវិញ ក៏ត្រូវធ្វើតាមនាយកខុទ្ទកាល័យដែរ ។ នាយកខុទ្ទកាល័យមានភារកិច្ចបញ្ជូនលិខិត និង សំណុំរឿងទាំងនេះតាមប្រភេទដូចតទៅ :

ក– ប្រភេទជូនជ្រាបជាពត៌មានត្រូវបញ្ជូនទៅនាយកដ្ឋានសាមីវិញដើម្បីរក្សាទុក។

ខ– ប្រភេទចុះហត្ថលេខាហើយ បញ្ជូនទៅនាយកដ្ឋានកិច្ចការទូទៅ ដើម្បីវាយត្រាចុះលេខថ្ងៃ ខែ និងបញ្ជូនទៅទិសដៅ ឬ នាយកដ្ឋានសាមីដើម្បីចាត់ការបន្ត ។

គ– ប្រភេទសុំសេចក្តីណែនាំ ឬ សំរេច បញ្ជូនត្រឡប់មករដ្ឋលេខាធិការវិញ ដើម្បីចាត់ការអនុវត្តន៍តាមសេចក្តីណែនាំ ឬ សេចក្តីសំរេចរបស់រដ្ឋមន្ត្រី ។ ក្នុងករណីនេះ សំណុំលិខិតត្រូវធ្លាក់មកសាមីនាយកដ្ឋានវិញ រួចឡើងតាមលំដាប់ថ្នាក់ម្តងទៀត ។

**IV- ករណីការងារប្រញាប់បន្ទាន់** : លិខិត និង ទូរសារ ( Fax )

**ប្រការ១៦** : នៅពេលទទួលសំណុំរឿងការងារប្រញាប់ណាមួយភ្លាម ការិយាល័យរបៀបត្រូវចុះលេខអោយបានត្រឹមត្រូវ ហើយបញ្ជូនភ្លាមទៅអគ្គលេខាធិការ ។ អគ្គលេខាធិការមានភារកិច្ចចាត់បញ្ជូនសំណុំរឿង :

ក–ថតចម្លងជូនរដ្ឋមន្ត្រី ( Original ) តាមលោកនាយកខុទ្ទកាល័យ ។

ខ-ឯកឧត្តមរដ្ឋលេខាធិការស្នើសុំចាត់ការបន្ទាន់

១-ស្នើសុំមតិ ឬ សេចក្តីសំរេចរបស់រដ្ឋមន្ត្រី

២-តាមរយៈអនុរដ្ឋលេខាធិការទៅនាយកដ្ឋាននានា

គ-នាយកដ្ឋានសាមី ដើម្បីត្រៀមអនុវត្ត ។

**V-ករណីការងារសម្ងាត់ និងលិខិតផ្ទាល់ខ្លួន :**

**ប្រការ១៧** : នៅពេលទទួលបានភ្លាម ការិយាល័យរបៀបត្រូវវាយត្រាចុះបញ្ជី ហើយចុះលេខលើស្រោមសំបុត្ររួចបញ្ជូនលិខិតទាំងស្រោមនេះភ្លាមដោយឥតមានហែកទៅជូនទិសដៅ (Destinataires) បើសិនជាលិខិតដាក់ចំឈ្មោះ ឬ ទៅរដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការ តាមរយៈនាយកខុទ្ទកាល័យ បើសិនជាលិខិតផ្លូវការរបស់ក្រសួង ។

**ប្រការ១៨** : ប្រកាសនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រការ១៩** : ឯកឧត្តម រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គលេខាធិការ នាយកខុទ្ទកាល័យ រដ្ឋមន្ត្រី និងប្រធាននាយកដ្ឋានទាំងអស់ នៃក្រសួងត្រូវទទួលបន្ទុក និង អនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខា ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**អ៊ឹង ហួត**

* * *

## ៤ - ទីស្តីការរដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម

## ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ១៩៩៥

**ប្រកាសលេខ : ១១០/៩៥ ពម.ប្រក**

**ស្តីពី ការលុបឈ្មោះមន្ត្រី រាជការ**

- បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩៣ របស់ក្រុម ប្រឹក្សារដ្ឋមន្ត្រី ។
- យោងប្រកាសលេខ ០៨៣.៩៥ ពមប្រក ចុះថ្ងៃទី ៣០ ខែ ៣ ឆ្នាំ ១៩៩៥ និង ប្រកាសលេខ ០៨៧.៩៥ ពមប្រក ចុះថ្ងៃទី ៣១ ខែ ៣ ឆ្នាំ ១៩៩៥ ។
- បានឃើញសំណើកែតម្រូវប្រាក់ឧត្ថម្ភគោលនយោបាយមន្ត្រី រាជការស្ម័គ្រចិត្តសុំឈប់ បំពីការងារ លេខ ២៣៩ ពមរ ចុះថ្ងៃទី ៤ ខែ មេសា ឆ្នាំ ១៩៩៥

## **សំរេច**

**ប្រការ ១ :** លុបឈ្មោះមន្ត្រីរាជការ ចំនួន ៨ នាក់ ចេញពីក្របខ័ណ្ឌមន្ទីរពេទ្យមានរាជធានីភ្នំពេញចាប់ពីថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ១៩៩៥ នេះទៅ ដោយសាមីជនស្ម័គ្រចិត្តសុំឈប់បំពីការងារ ដូចមានរាយនាមខាងក្រោម :

| | |
|---|---|
| ១- លោក ញ៉ែម ម៉ារី | ៥- លោក ពត វិន |
| ២- លោក វ៉ែន វឿន | ៦- លោក គង់ ស៊ីចាន់ |
| ៣- លោក អ៊ុង សំអុល | ៧- លោក ឈឹម សារិន |
| ៤- លោក ហេង ស្រេង | ៨- អ្នកស្រី សុក ច័ន្ទតារា |

**ប្រការ ២ :** កែតម្រូវប្រកាសលេខ ០៨៣.៩៥ ពម.ប្រក និងប្រកាសលេខ ០៨៧.៩៥ ពម.ប្រក ដែលមានការភ័ន្តច្រឡំលើតួលេខប្រាក់បៀវត្សរបស់សាមីជនម្នាក់ ៗ ដូចមានខាងក្រោម ÷

១- លោក ញ៉ែម ម៉ារី ៥២.៧៥០៛, គុណ ១០ : ៥២៧.៥០០,០០
២- លោក វ៉ែន វឿន ៣៤.៣២០៛, គុណ ១០ : ៣៤៣.២០០៛,០០
៣- លោក អ៊ុង សំអុល ៤៥.២១០៛, គុណ ១០ : ៤៥២.១០០៛,០០
៤- លោក ហេង ស្រេង ៥២.៧៥០៛, គុណ ១០ : ៥២៧.៥០០៛,០០

៥– លោក ពក រិន ៥២.៧៥០៛, គុណ ១០: ៥២៧.៥០០៛,០០
៦– លោក គង់ ស៊ីចាន់ ៥០.១១០,៛ គុណ ១០: ៥០១.១០០៛,០០
៧– លោក ឈឹម សារិន ៣៨.៨៨០៛, គុណ ១០: ៣៨៨.៨០០៛,០០
៨– អ្នកស្រី សុក ចំនួតារា ៥២.៦១០៛, គុណ ១០: ៥២៦.១០០៛,០០

**ប្រការ ៣ :** អគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ មន្ទីរគតិយុត្តរាជធានីភ្នំពេញ និង សាមីខ្លួន មានភារៈអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**អឿង មុណី**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ១៩៩៥

**ប្រកាស ១១១/៩៥ ពមប្រក**

**ស្តីពីការផ្លាស់ប្តូរកន្លែងរបស់មន្ត្រី រាជការ**

– បានឃើញព្រះរាជក្រឹត្យ ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ វរ្ម័ន** ចុះថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
– ពិនិត្យលើសំណើសុំផ្លាស់កន្លែងធ្វើការរបស់សាមីខ្លួន ។

**សំរេច**

**ប្រការ ១ :** យល់ព្រមផ្លាស់ប្តូរកន្លែងធ្វើការជូនលោក **សួន គីមស្រ៊ន** អនុប្រធាននាយកដ្ឋានដំណឹងក្នុងប្រទេស អគ្គនាយកដ្ឋានទីភ្នាក់ងារសារពត៌មានខ្មែរ អោយទៅបំរើការងារនៅស្នងការដ្ឋាននគរបាលខេត្តកណ្តាល ។

**ប្រការ ២ :** ប្រាក់បៀវត្ស និង ប្រាក់ឧបត្ថម្ភផ្សេង ៗ របស់សាម៉ីខ្លួន អគ្គនាយកដ្ឋានទីភ្នាក់ងារសារពត៌មានខ្មែរ ត្រូវផ្ទេរផ្តាច់ទៅអោយស្នងការនគរបាលខេត្តកណ្តាល ចាប់ពីថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ១៩៩៥ នេះទៅ ។

**ប្រការ ៣ :** ទីភ្នាក់ងារសារពត៌មានខ្មែរ នាយកដ្ឋានផែនការ គណនេយ្យហិរញ្ញវត្ថុ នាយកដ្ឋានបុគ្គលិក រដ្ឋបាល និង សាម៉ីខ្លួន មានភារៈអនុវត្តតាមប្រកាស ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**អៀង មូលី**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ១៩៩៥

**ប្រកាស ១១២/៩៥ ពម.ប្រក**

**ស្តីពីការតាំងស៊ប់ក្នុងក្របខ័ណ្ឌ**

- បានឃើញព្រះរាជក្រឹត្យ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ចុះថ្ងៃទី០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- យោងលិខិតលេខ ០៧-៩៤ សសរ.មប.ក្រខ ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៩៤ របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ស្តីពីការបែងចែកសិស្ស និស្សិតចំនួន ១.៤១៨ នាក់ ។
- យោងសេចក្តីសំរេចលេខ ០០៨-៩៤ ពម.សរ ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៤ របស់ក្រសួងពត៌មាន ស្តីពីការបែងចែកសិស្ស និស្សិត ១៩ នាក់ ទៅតាមអង្គភាពចំណុះ ។
- យោងលិខិតរបស់ទីភ្នាក់ងារសារពត៌មានខ្មែរលេខ ១១៣ សពខ ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ១៩៩៥ ស្តីពីការស្នើសុំបំពេញសិទ្ធិជូនលោក **ឆិត ស្រ៊ា**

បុគ្គលិកនាយកដ្ឋាន បច្ចេកទេស ។

– ពិនិត្យលទ្ធភាព និង សមត្ថភាពរបស់លោក **ឆិន ស្រ៊**

**សម្រេច**

**ប្រការ ១** : រៀបចំការតាំងស៊ប់ក្នុងក្របខ័ណ្ឌជូនលោក **ឆិន ស្រ៊** កម្មករបច្ចេកទេសជួសជុលវិទ្យុ ម៉ាញ៉េ បច្ចុប្បន្នបុគ្គលិកនាយកដ្ឋានបច្ចេកទេស នៃទីភ្នាក់ងារសារពត៌មានខ្មែរ « AKP » អោយស្ថិតក្នុងប្រភេទ គ I ១ : ២៦.៤០០៛,00 តាមគោលការណ៍ ។

**ប្រការ ២** : រៀបចំបៀវត្សថ្មី និង រាល់ផលប្រយោជន៍ផ្សេង ៗ របស់សាម៉ីខ្លួន ចាប់ពីថ្ងៃទី ០១ ខែ ឧសភា ឆ្នាំ ១៩៩៥ តទៅ ។

**ប្រការ ៣** : ទីភ្នាក់ងារសារពត៌មានខ្មែរ «AKP» នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានផែនការហិរញ្ញវត្ថុ ការិយាល័យបុគ្គលិក និង សាម៉ីខ្លួន មានភារៈអនុវត្ត តាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**អៀង មូលី**

* * *

រាជធានីភ្នំពេញ,ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ១៩៩៥

**ប្រកាសលេខ : ១១៣/៩៥ ពម.ប្រក**

**ស្តីពីការបញ្ចូលជាគ្រូបខ័ណ្ឌពេញសិទ្ធិរបស់គ្រូស្វ័ន**

– បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣

– បានឃើញសេចក្តីសំរេចលេខ ៨៩ សសរ ចុះថ្ងៃទី ១០–១០–១៩៩៣ របស់ក្រុម ប្រឹក្សារដ្ឋមន្ត្រី ស្តីពីប្រព័ន្ធបៀវត្សកម្មាភិបាល បុគ្គលិក កម្មកររដ្ឋ

– យោងតាមប្រកាសលេខ ០៨ ព.ម ចុះថ្ងៃទី ០៥–៧–១៩៩៣ ស្តីពីធ្វើការសាកល្បង មន្ត្រី រាជការ

- យោងតាមសំណើសុំបំពេញសិទ្ធិជូនមន្ត្រី រាជការ របស់អគ្គនាយកដ្ឋានវិទ្យុជាតិ ចុះថ្ងៃ ទី ២០ ខែ មេសា ឆ្នាំ ១៩៩៥
- តាមការពិនិត្យលើសមត្ថភាពការងាររបស់សាម៉ីខ្លួន

**សំរេច**

**ប្រការ ១ :** ទទួលស្គាល់ និង បំពេញសិទ្ធិជូនលោក **ឈឹម គីមឈន** អ្នកបច្ចេកទេសថ្នាក់ឧត្តម ចូលជាក្របខ័ណ្ឌពេញសិទ្ធិ របស់អគ្គនាយកដ្ឋានវិទ្យុជាតិកម្ពុជា នៃក្រសួងពត៌មាន ។

**ប្រការ ២ :** ប្រាក់បៀវត្ស និងប្រាក់ឧត្តម្ភផ្សេង ៗ របស់សាម៉ីខ្លួន ត្រូវបានទទួលមួយរយភាគរយតាមការកំណត់របស់រដ្ឋ ចាប់ពីថ្ងៃទី ០១-៦-១៩៩៥ តទៅ ។

**ប្រការ ៣ :** អគ្គនាយករដ្ឋានវិទ្យុជាតិកម្ពុជា នាយកដ្ឋានរដ្ឋបាលបុគ្គលិក នាយកដ្ឋានគណនេយ្យ ផែនការ ហិរញ្ញកិច្ច និង សាមីខ្លួន ត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**អៀង មូលី**

* * *

## ៥— ទីស្តីការរដ្ឋមន្ត្រី ក្រសួងទេសចរណ៍

## ប្រកាស

ភ្នំពេញ , ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ១៩៩៥

**ប្រកាសលេខ : ០១៧ គនចប្រ**

**ស្តីពីការតែងតាំងជាបណ្តោះអាសន្ន ចំពោះមន្ត្រី**

**ថ្នាក់ការិយាល័យ សំរាប់មន្ទីរទេសចរណ៍ ក្រុងកែប**

## រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រ កម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- យោងប្រកាសលេខ ៨៩៣ កទច ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៤ ស្ដីពីការបង្កើតរចនាសម្ព័ន្ធ ថ្នាក់មន្ទីរសំរាប់ទេសចរណ៍ក្រុងកែប
- យោងប្រកាសលេខ ០២ កទច ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៥ ស្ដីពីការតែងតាំង ជាបណ្ដោះអាសន្នចំពោះមន្ត្រីរាជការ និង ក្របខ័ណ្ឌមន្ទីរទេសចរណ៍ ក្រុងកែប
- យោងលិខិតលេខ ១០ សណក្រក ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ១៩៩៥ ស្ដីពីការសុំ តែងតាំងមន្ត្រី ថ្នាក់ការិយាល័យ សំរាប់មន្ទីរទេសចរណ៍ ក្រុងកែប
- យោងតាមសំណូមពរភារកិច្ចចាំបាច់ នៃការងារអភិវឌ្ឍន៍ វិស័យទេសចរណ៍

### សំរេច

**ប្រការ ១ :** តែងតាំង :

មន្ទីរទេសចរណ៍ក្រុងកែបមានបីការិយាល័យ :

ក– <u>ការិយាល័យឧស្សាហកម្មទេសចរណ៍ និង ផែនការ</u> :

១– លោក **សុខ ធន្ណៈ** ជាប្រធាន

២– លោក **ម៉ុក គាំង** ជាអនុប្រធាន

ខ– <u>ការិយាល័យអភិវឌ្ឍន៍វប្បធម៌ និង បណ្ដុះបណ្ដាល</u> :

១– កញ្ញា **ជួង កែវចិន្ដា** ជាប្រធាន

២– អ្នកស្រី **ខឹម សុខា** ជាអនុប្រធាន

គ– <u>ការិយាល័យរដ្ឋបាល និង ហិរញ្ញវត្ថុ</u> :

១– លោក **ម៉ែន ឃាត់** ជាអនុប្រធាន

**ប្រការ ២ :** នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានគ្រប់គ្រងទេសចរណ៍ខេត្ត-ក្រុង ប្រធាននាយកដ្ឋានរដ្ឋបាលទូទៅ ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ ប្រធានមន្ទីរទេសចរណ៍ក្រុងកែប និង សាមីខ្លួន ត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រដ្ឋមន្ត្រីក្រសួងទេសចរណ៍

ហត្ថលេខា និង ត្រា

**វេង សេរីវុឌ្ឍ**

* * *

## ៦– ទីស្តីការរដ្ឋមន្ត្រី ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

### ប្រកាស

ភ្នំពេញ , ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ១៩៩៥

**ប្រកាសលេខ : ១១១ ប្រ.ក.វ.វ.ស.ខ**

**ស្តីពីការបង្កើតគណៈមេប្រយោគប្រលងយកសញ្ញាបត្រសិល្បៈ**

**ស្នាតកបត្រសិល្បៈឆ្នាំ ១៩៩៤–៩៥**

**រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ**

– បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

– បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទ សម្តេច **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា ។

- តាមសំណើរបស់សកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ

**សម្រេច**

**មាត្រា ១** : ត្រូវបានតែងតាំងជាគណៈមេប្រយោគសំរាប់ការប្រលងយកសញ្ញាប័ត្រសិល្បៈ និង ស្ទាត កប័ត្រសិល្បៈ ឆ្នាំសិក្សា ១៩៩៤-៩៥ ដែលនឹងប្រព្រឹត្តិទៅចាប់ពីថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ១៩៩៥ តទៅ ។

**មាត្រា ២** : គណៈមេប្រយោគ ដែលសមាសភាពរួមមាន :

១- អ្នកអង្គម្ចាស់រដ្ឋលេខាធិការ **ស៊ីសុវត្ថិ ស៊ីរីវុឌ្ឍ ម៉ាណនារ៉ា** ប្រធាន

២- លោក **ឧុយ តៀន** អនុប្រធាន

៣- លោក **ឡោ សាន** -

៤- លោក **ស្វៀន ឈយ** សមាជិក

៥- លោក **ទ៉ែន ផាត** -

៦- លោក **ម៉ៅ ឡឿង** -

៧- លោក **អ៊ឹក សុជាតិ** -

៨- តំណាងក្រសួងអប់រំយុវជន និង កីឡា សមាជិក

៩- លោក **ចាប ស្ទួន** សមាជិក

**មាត្រា ៣** : ប្រធានគណៈមេប្រយោគមានសិទ្ធិ បង្កើតអនុគណៈកម្មការឬក្រុមទាំងឡាយដែលជាតម្រូវការចាំបាច់ ក្នុងដំណើរការប្រលង ។

**មាត្រា ៤** : អគ្គនាយកដ្ឋានរដ្ឋបាល សកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ព្រមទាំងសាម៉ីខ្លួន មានភារ កិច្ចអនុវត្តប្រកាសនេះ ។

រដ្ឋលេខាធិការ

ព្រះហស្តលេខា និង ត្រា

**ស៊ីសុវត្ថិ ស៊ីរីវុឌ្ឍ ម៉ាណនារ៉ា**

* * *

## ៧— ទីស្ដីការរដ្ឋមន្ត្រី ក្រសួងអប់រំយុវជន និង កីឡា

## ប្រកាស

ភ្នំពេញ,ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ១៩៩៥

**ប្រកាសលេខ ៦៤៣ អយក ប្រក**

**ស្ដីពីការប្ដូរឈ្មោះវិទ្យាល័យស្វាយប៉ោ មកជាវិទ្យាល័យនេតយ៉ង់ និងវិទ្យាល័យបាត់ដំបង មកជាវិទ្យាល័យព្រះមុនីវង្ស នៅខេត្តបាត់ដំបង**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេច **នរោត្តម សីហនុ វរ្ម័ន្ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញ ក្រឹត្យ–ច្បាប់លេខ៣០ ក្រ.ច ចុះថ្ងៃទី ២០ វិច្ឆិកា ឆ្នាំ ១៩៨៦ ស្ដីពីប្រព័ន្ធអប់រំចំណេះទូទៅ
- យោងសំណើរបស់មន្ទីរអប់រំយុវជននិង កីឡាខេត្តបាត់ដំបងស្ដីពីការសុំប្ដូរឈ្មោះវិទ្យាល័យស្វាយប៉ោ និងវិទ្យាល័យបាត់ដំបងដោយមានការឯកភាពពីអភិបាលខេត្តបាត់ដំបង
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានចំណេះទូទៅនិងមត្តេយ្យសិក្សា .

## សម្រេច

**ប្រការ ១ :** អនុញ្ញាតអោយប្ដូរឈ្មោះវិទ្យាល័យស្វាយប៉ោ បច្ចុប្បន្នមកឈ្មោះដើម «វិទ្យាល័យនេតយ៉ង់ » និងប្ដូរឈ្មោះវិទ្យាល័យបាត់ដំបងបច្ចុប្បន្ន មកឈ្មោះដើម «វិទ្យាល័យព្រះមុនីវង្ស» ដូចពីសម័យសង្គមរាស្ត្រនិយម ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រការ ២ :** បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៣ :** ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា ប្រធាននាយកដ្ឋានចាត់តាំង និងប្រធាននាយកដ្ឋានផែនការ ហិរញ្ញកិច្ច នៃក្រសួងអប់រំ យុវជន និង កីឡា មានភារកិច្ចរៀង ៗ ខ្លួនអនុវត្តប្រកាសនេះ ។

ជ–រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

**គា សាហាន**

* * *

ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ១៩៩៥

**ប្រកាសលេខ ៦៤៤ អយក ប្រក**

**ស្តីពីការរៀបចំប្រព្រឹត្តិទៅ នៃការប្រលងសញ្ញាបត្រមធ្យមសិក្សាភូមិ ២**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញក្រឹត្យ ច្បាប់លេខ ៣០ ក្រច ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ១៩៨៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ។
- បានឃើញលិខិតខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រីលេខ ២២៣៧ សជណ អវ ចុះថ្ងៃទី ១៩–១១–៩០ ស្តីពីការប្តូរឈ្មោះសាលារៀនចំណេះទូទៅ ។

– បានឃើញប្រកាសក្រសួងលេខ ២៣២៩ចុះថ្ងៃទី ១៧–៥–១៩៨០ ស្ដីពីការបង្កើតអោយមានការប្រលងសញ្ញាប័ត្រកំរិតសិក្សាទី ៣ ។

– បានឃើញ សេចក្ដីសំរេចរបស់រដ្ឋមន្ត្រី ក្រសួងអប់រំយុវជន និង កីឡា លេខ ៤០ អយក សសរ ស្ដីពីការរៀបចំប្រលងសញ្ញាប័ត្រមធ្យមសិក្សាកំរិត ២ ។

**ប្រការ ១ :** មណ្ឌលប្រលងសញ្ញាប័ត្រមធ្យមសិក្សាកំរិត ២ លើកទី ១ និងលើកទី ២ ត្រូវកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា រៀងរាល់ឆ្នាំសិក្សា ។

**ប្រការ ២ :** ប្រធានមន្ទីរអប់រំ យុវជន និង កីឡា ខេត្ត–ក្រុង និង នាយកគ្រឹះស្ថានសិក្សាដែលគ្រឹះស្ថានត្រូវបានកំណត់ជាមណ្ឌល ប្រឡងមានភារៈរៀបចំបន្ទប់ប្រឡង សៀវភៅ រូតថត បេក្ខជន បញ្ជីផ្សេងៗ និងសំភារៈចាំបាច់សំរាប់ការប្រព្រឹត្តិទៅនៃការប្រលងអោយ ហើយស្រេចមុនបើកសម័យប្រលង ។

– ចំពោះសាលាក្រោមឱវាទផ្ទាល់ នៃក្រសួងអប់រំយុវជន និងកីឡា នាយក វិទ្យាល័យ ក៏ត្រូវអនុវត្តដូចមណ្ឌលនានាដែរ តាមការណែនាំរបស់នាយកដ្ឋាន ចំណេះទូទៅ និងមធ្យមសិក្សា ។

**ប្រការ ៣ :** នឹងអាចចុះឈ្មោះលើកទី ១ បាន បេក្ខជនទាំងឡាយណាជាសិស្សថ្នាក់ទី ១១ នៃវិទ្យាល័យសាធារណៈ និងឯកជនដែលបានរៀនចប់កម្មវិធីសិក្សាថ្នាក់ទី ១១ ។ ពាក្យសុំចុះឈ្មោះប្រលងមានបិទតែមត្រូវស្នើសុំទៅរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា តាមរយៈឋានានុក្រម ។

**ប្រការ ៤ :** នឹងអាចអនុញ្ញាតអោយចូលរួមប្រលងលើកទី ២ បាន :

– បេក្ខជនដែលប្រលងធ្លាក់លើកទី ១ និងបានពិន្ទុសរុប នៃការប្រលងលើកទី ១ ចាប់ពី ៣/៥ នៃពិន្ទុ ២៥ (គឺពិន្ទុចាប់ពី ១៥) ឡើងទៅ ។

– បេក្ខជនដែលបានដាក់ពាក្យសុំប្រលងលើកទី ១ តែអាក់ខានពុំបានចូលរួម ប្រលង ឬបានចូលរួមប្រលងពុំបានគ្រប់មុខវិជ្ជា ដោយមូលហេតុមានជម្ងឺ ឬ គ្រោះថ្នាក់ផ្សេងៗជាក់ស្ដែងដែលមានលិខិតបញ្ជាក់ច្បាស់លាស់ពីគ្រូពេទ្យ និងអាជ្ញាធរ មានសមត្ថកិច្ច ។

**ប្រការ ៥ :** អាចសុំចុះឈ្មោះប្រលងសញ្ញាប័ត្រមធ្យមសិក្សាកំរិត ២ ជាបេក្ខជនស្វ័យវិនបាន អតីតបេក្ខជនដែលប្រលងធ្លាក់សញ្ញាប័ត្រមធ្យមសិក្សាកំរិត ២ ។

**ប្រការ ៦** : បេក្ខជនត្រូវភ្ជាប់ នឹងពាក្យសុំប្រលងរបស់ខ្លួននូវ :

-វិញ្ញាបនប័ត្របណ្ដោះអាសន្នមធ្យមសិក្សាកំរិត ២ ១ សន្លឹក

-សលាកប័ត្រឯកត្តជនទំហំ ១៥សម×២១សម មានបិទរូបថត ថតថ្មី ថតចំពីមុខ ទំហំ ៤សម×៦សម ចំនួន ៤ សន្លឹក

-បង្កាន់ដៃបង់សិទ្ធិប្រលង ១ ច្បាប់

-រូបថត ថតថ្មី ថតចំពីមុខ ទំហំ ៤សម×៦សម «រូបថតដែលបាន បិទលើសលាក ប័ត្រឯកត្តជន» ចំនួន ៥ សន្លឹក

-សៀវភៅសិក្ខាគារិក «ចំពោះសិស្សសាលាឯកជន»

**ប្រការ ៧** : ពាក្យសុំឈ្មោះប្រលងលើកទី ១ និងលើកទី ២ នឹងត្រូវប្រមូលផ្ដុំតាមគ្រឹះស្ថានសិក្សាដែលខ្លួនសិក្សា ។ នាយកគ្រឹះស្ថានសិក្សា ត្រូវប្រមូលសំនុំលិខិតរបស់បេក្ខជនបញ្ជូនទៅមន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុង ដើម្បីធ្វើការបែងចែកឈ្មោះបេក្ខជនតាមលំដាប់អក្សរទៅតាមបន្ទប់ប្រលង ។

**ប្រការ ៨** : បេក្ខជនដែលបានទទួលការយល់ព្រមពីក្រសួងអប់រំយុវជន និងកីឡា « នាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា » អោយប្រលងលើកទី ២ មិនបាច់ដាក់ពាក្យសុំប្រលងទៀតទេ លើកលែងតែបេក្ខជនដែលបានដាក់ពាក្យលើកទី ១ តែអាក់ខានពុំបានចូលរួមប្រលង ឬចូលរួមប្រលងពុំបានគ្រប់មុខវិជ្ជា ដោយមូលហេតុមានជំងឺ ឬគ្រោះថ្នាក់ផ្សេងៗ ជាក់ស្ដែង ។

-បេក្ខជនដែលត្រូវដាក់ពាក្យសុំប្រលងលើកទី ២ សារជាថ្មីត្រូវដាក់ពាក្យនៅនាយក ដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា ដោយមានភ្ជាប់ជាមួយនូវសំបុត្រពេទ្យ និង លិខិតបញ្ជាក់ពីក្រសួងមានសមត្ថកិច្ច ។

**ប្រការ ៩** : បេក្ខជនស្វ័យរិនត្រូវដាក់ពាក្យសុំប្រលងលើកទី ១ ដោយមានបញ្ជាក់សម័យប្រលង មណ្ឌលប្រលង លេខបន្ទប់ លេខតុ នៃសម័យប្រលងមុន នៅតាមមន្ទីរអប់រំយុវជន និងកីឡា ខេត្ត-ក្រុង ដែលសាមីខ្លួនបានសុំប្រលងពីមុន ឬនៅនាយកដ្ឋានចំណេះទូទៅ នៃក្រសួងអប់រំយុវជន និងកីឡា ។ មន្ទីរអប់រំយុវជន និងកីឡា ខេត្ត-ក្រុងត្រូវធ្វើបញ្ជីរាយនាមបេក្ខជនស្វ័យរិន ផ្ញើទៅក្រសួងអប់រំ

យុវជន និងកីឡា «នាយកដ្ឋានចំណេះទូទៅ និងមធ្យមសិក្សា» ដើម្បីពិនិត្យ និងសំរេចលើបេក្ខភាព ។

**ប្រការ ១០** : ការក្លែងបន្លំផ្សេងៗពីសំណាក់បេក្ខជន ត្រូវទទួលការបញ្ឈប់មិនអនុញ្ញាត អោយប្រលងចំនួនពីរឆ្នាំ ។

**ប្រការ ១១**: មណ្ឌលប្រលងនីមួយៗ ត្រូវមានគណៈមេប្រយោគ មានអនុប្រធាន [illegible] សមាជិក [illegible] ។

**ប្រការ ១២** : [illegible] ដោយអ្នក [illegible] ។

**ប្រការ ១៣** : ចំនួនអនុរក្ស [illegible] មណ្ឌលប្រឡង ត្រូវ [illegible] និង ២,៥ [illegible]

**ប្រការ ១៤** : បន្ទប់ប្រលងនីមួយៗត្រូវដាក់បេក្ខជនក្រុម ២៥ «ម្ភៃប្រាំនាក់» [illegible] នៅសល់ពី ០៥ «ប្រាំ» នាក់ឡើងទៅ ត្រូវដាក់ក្នុងបន្ទប់មួយដោយឡែក។

**ប្រការ១៥** : ប្រធានគណៈមេប្រយោគ នៃ មណ្ឌលនីមួយៗ ជាអ្នកទទួលខុសត្រូវរួមក្នុងដំណើរការប្រព្រឹត្តិទៅ នៃការប្រលងទាំងផ្នែករដ្ឋបាល ទាំងផ្នែកបច្ចេកទេស ចំពោះក្រសួងអប់រំយុវជន និងកីឡា ។

**ប្រការ១៦** : ប្រធានគណៈមេប្រយោគត្រូវសហការឬធ្វើអន្តរាគមន៍ដល់អាជ្ញាធរមានសមត្ថកិច្ចនានាក្នុងខេត្ត–ក្រុង នៃមណ្ឌលប្រលងក្នុងករណីចាំបាច់ ដើម្បីរក្សារបៀបរៀបរយក្នុងពេលប្រលង ។

**ប្រការ ១៧** : មណ្ឌល ឬអនុមណ្ឌលប្រលងណាមួយដែលមិនមានភាពប្រក្រតី តាមលក្ខការណ៍នៃការប្រលង គណៈមេប្រយោគ នៃមណ្ឌល ឬអនុមណ្ឌលនោះត្រូវរាយការណ៍ជាបន្ទាន់មកគណៈមេប្រយោគទូទាំងប្រទេស ដើម្បីដោះស្រាយ ឬសុំការសំរេចពីក្រសួងអប់រំ យុវជន និងកីឡា ។

**ប្រការ ១៨** : ប្រធានគណៈមេប្រយោគត្រូវបែងចែកភារកិច្ចដល់អនុប្រធាន និងសមាជិកគណៈមេប្រយោគអោយទទួលខុសត្រូវតាមមុខងាររៀងៗខ្លួន ។

**ប្រការ ១៩** : ភារកិច្ច នៃគណៈកម្មការ អនុគណៈកម្មការ និងសមាជិកនៃគណៈមេប្រយោគ នឹងមាន ចែងក្នុងសេចក្តីណែនាំមួយរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

**ប្រការ ២០** : នៅពេលប្រលងបេក្ខជនទាំងឡាយ ត្រូវមកប្រលងអោយទាន់ពេលកំណត់ ការមកប្រលងយឺតយ៉ាវលើសពី ១៥ នាទី មិនអនុញ្ញាតអោយចូលប្រឡងឡើយ ។ នៅពេលចូលប្រលង បេក្ខជនត្រូវមានលិខិតសំគាល់ខ្លួន មានបិទរូបថត និងមានបញ្ជាក់ច្បាស់លាស់ ។ ជនដែលគ្មានលិខិតសំគាល់ខ្លួនមិនអនុញ្ញាតអោយចូលប្រលងឡើយ ។

**ប្រការ២១** : ហាមមិនអោយមានការប្រលងជំនួសគ្នាឡើយ ។

**ប្រការ២២** :មិនអនុញ្ញាតអោយបេក្ខជនទាំងឡាយយកឯកសារនានាជាប់នឹងខ្លួនចូលក្នុងបន្ទប់ប្រលងជាដាច់ខាត ។

**ប្រការ២៣** :បេក្ខជនទាំងឡាយ ត្រូវអង្គុយតាមលេខតុ របស់ខ្លួនគ្រប់វិញ្ញាសា ។

**ប្រការ២៤** : បេក្ខជនទាំងឡាយត្រូវធ្វើវិញ្ញាសាលើក្រដាសប្រលង ដែលអនុរក្សចែកអោយ ។ បេក្ខជនមិនត្រូវធ្វើសញ្ញាអ្វីលើក្រដាសប្រលង ដែលនាំអោយស្គាល់ថា ជាសន្លឹកកិច្ចការរបស់សាមីខ្លួនជាដាច់ខាត ។ សន្លឹកកិច្ចការណាដែលមានសញ្ញាសំគាល់ត្រូវបានពិន្ទុសូន្យ ។

**ប្រការ២៥** : នៅពេលធ្វើវិញ្ញាសាប្រឡង មិនអនុញ្ញាតអោយបេក្ខជនលួចចំលង ឬបំណងលួចចំឡងជាដាច់ខាត ។ កំហុស នៃការលួចចំលង ឬបំណងលួចចំលង នឹងមានចែងក្នុងអត្ថបទមួយ ។

**ប្រការ២៦** : វិញ្ញាសា និងថេរវេលា នៃការប្រលងសញ្ញាបត្រមធ្យមសិក្សាកំរិត ២ លើកទី ១ និងលើកទី ២ ត្រូវកំណត់ដូចតទៅ :

| | |
|---|---|
| ១–តែងសេចក្តី | រយៈពេល ៣ ម៉ោង |
| ២–ភូមិវិទ្យា ជីវវិទ្យា | រយៈពេល ២ ម៉ោង |
| ៣–រូបវិទ្យា គីមី | រយៈពេល ៣ ម៉ោង |
| ៤–ទស្សនវិជ្ជា | រយៈពេល ២ ម៉ោង |
| ៥–គណិតវិទ្យា | រយៈពេល ៣ ម៉ោង |

**ប្រការ២៧** :ប្រធានវិញ្ញាសាប្រលង ត្រូវយកតាមកម្មវិធីថ្នាក់ទី ១១ នៃមធ្យមសិក្សាកំរិត ២ ។ វិញ្ញាសាទាំងឡាយជាវិញ្ញាសាសរសេរទាំងអស់ ។

**ប្រការ២៨** : ប្រធានវិញ្ញាសាទាំងឡាយ ត្រូវរើសដោយគ្រូបង្រៀនថ្នាក់ទី ១១ ហើយជ្រើសរើស ឬតាក់តែងដោយមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ។

**ប្រការ២៩** : ប្រធានវិញ្ញាសាទាំងឡាយ ដែលបានជ្រើសរើសរួចហើយ ត្រូវដាក់ក្នុងស្រោមសំងាត់បិទជិត និងប្រថាប់ត្រា ហើយត្រូវបញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ចដែលមានមណ្ឌលប្រលងអោយថែរក្សាទុក ៤៨ ម៉ោងមុនពេលប្រកាសចាប់ផ្តើមប្រឡង ។

**ប្រការ៣០** : អាជ្ញាធរមានសមត្ថកិច្ច ដែលថែរក្សាវិញ្ញាសាទាំងនោះ ត្រូវប្រគល់អោយប្រធានគណៈមេប្រយោគចំពោះមុខសមាជិកនៅថ្ងៃចាប់ផ្តើមការប្រលងមួយម៉ោង មុនពេលបើកសម័យប្រលង ។

**ប្រការ៣១** : ការប្រគល់អោយ និងការទទួលយកវិញ នូវប្រធានវិញ្ញាសាប្រលងត្រូវមានការទទួលខុសត្រូវទាំងសងខាង ដោយមានកំណត់ហេតុជាផ្លូវការផង ។

**ប្រការ៣២** : វិញ្ញាសានីមួយ ៗ ត្រូវមានចំនួនស្មើនឹងបន្ទប់ប្រលង ។ បើខ្វះត្រូវចំលងបន្ថែមបង្គ្រប់ភ្លាម ។

**ប្រការ៣៣** : វិញ្ញាសានិមួយ ៗ ត្រូវអោយពិន្ទុពីសូន្យដល់ដប់ ហើយពុំមានមេគុណទេ ។ នឹងគិតជូចសូន្យចំពោះវិញ្ញាសាដែលបេក្ខជនពុំព្រមប្រគល់ជូនដល់គណៈ មេប្រយោគ និងចំពោះវិញ្ញាសាដែលបេក្ខជនអវត្តមានពុំបានមកធ្វើ ។

**ប្រការ៣៤** : វិញ្ញាសាសរសេរនីមួយ ៗ ត្រូវកែដោយសមាជិកកំនែពីរនាក់ជាដាច់ខាតតាមតារាងអត្រាកំនែដែលគណៈមេប្រយោគបានសំរេច ។

**ប្រការ៣៥** : នឹងត្រូវប្រកាសថា ប្រលងជាប់សញ្ញាប័ត្រមធ្យមសិក្សាកំរិត ២ បេក្ខជនទាំងឡាយណាដែលបានពិន្ទុសរុបចំនួន ២៥ ឡើងទៅ ដោយឥតមានពិន្ទុសូន្យ ចំពោះវិញ្ញាសាណាមួយ (រូបវិទ្យា គីមី ជាវិញ្ញាសាមួយ ហើយភូមិវិទ្យា–ជីវវិទ្យា ក៏ជាវិញ្ញាសាមួយដែរ ) និងដោយឥតមានពិន្ទុស្មើនឹងមួយ ឬ តិចជាងមួយ ចំពោះវិញ្ញាសាគណិតវិទ្យា ឬវិញ្ញាសាតែងសេចក្តី ។

ក្នុងករណីចាំបាច់ គណៈមេប្រយោគអាចធ្វើសំរង់អោយជាប់បន្ថែម ក្រោយការយល់ព្រមពីក្រសួងអប់រំយុវជន និងកីឡា ទៅតាមភាពជាក់ស្តែង និងតាមសំណើរបស់គណៈមេប្រយោគ ហើយត្រូវមានកំណត់ហេតុបញ្ជាក់ច្បាស់លាស់ពីសំរង់បន្ថែម ។ បេក្ខជនស្វ័យវិនមិនធ្វើសំរង់អោយជាប់បន្ថែមឡើយ ។

**ប្រការ៣៦** : គណៈមេប្រយោគមណ្ឌលប្រលងនីមួយ ៗ ត្រូវប្រជុំពិភាក្សារួម ដើម្បីសំរេចលទ្ធផលនៃការប្រលង ។ កំណត់ហេតុ និងបញ្ជីចាំបាច់នានាភ្ជាប់មកជាមួយត្រូវបញ្ជូនទៅក្រសួងអប់រំយុវជន និងកីឡាជាពីរច្បាប់ដើម្បីសុំសេចក្តីយល់ព្រម ។

**ប្រការ៣៧** : និទ្ទេសត្រូវកំណត់មានដូចតទៅ :

ចាប់ពីពិន្ទុសរុប ២៥ ទៅពិន្ទុសរុប ៣២,២៥ និទ្ទេសមធ្យម

ចាប់ពីពិន្ទុសរុប ៣២,៥០ ទៅពិន្ទុសរុប ៣៩,៧៥ និទ្ទេសល្អបង្គួរ

ចាប់ពីពិន្ទុសរុប ៤០ ឡើងទៅ និទ្ទេស ល្អ

**ប្រការ៣៨** : នឹងត្រូវប្រកាសថាជាប់ជាបេក្ខជនប្រលងលើកទី ២ បេក្ខជនទាំងឡាយណាដែលមិនបានប្រកាសថា ប្រលងជាប់លើកទី ១ ហើយបានពិន្ទុសរុបពី ១៥ ឡើងទៅដោយមិនគិតពិន្ទុសូន្យចំពោះមុខវិជ្ជាណាមួយ ។

**ប្រការ៣៩** : ការប្រកាសថាជាប់ជាបេក្ខជនប្រលងលើកទី ២ នឹងត្រូវប្រកាស ក្រោយពីការប្រកាសលទ្ធផលប្រលងជាប់លើកទី ១ បន្ទាប់ពីមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ។

**ប្រការ៤០** : បទបញ្ញត្តិស្តីពីការរៀបចំប្រលងសញ្ញាប័ត្រមធ្យមសិក្សាកំរិត ២ ពីមុនៗទាំងឡាយណាដែលផ្ទុយពីសេចក្តីសំរេចនេះទុកជានិរាករណ៍ ។

**ប្រការ៤១** : ប្រធានមន្ទីរ និង ប្រធាននាយកដ្ឋានចំណេះទូទៅ និង មន្តេយ្យសិក្សា នៃក្រសួងអប់រំ យុវជន និងកីឡា ត្រូវចាត់ការតាមភារកិច្ចរៀងៗខ្លួន ដើម្បីអោយបានសំរេចតាមប្រកាសនេះ ។

ជ - រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

**គា សាខាន**

* * *

## ៨– ទីស្តីការរដ្ឋមន្ត្រី ក្រសួងអភិវឌ្ឍន៍ជនបទ

### ប្រកាស

ភ្នំពេញ ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ១៩៩៥

**ប្រកាសលេខ ១២២៧ អ.ជ.ប**

**ស្តីពីការចាត់តាំងមន្ត្រីរាជការ**

**រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ របស់ព្រះករុណា ព្រះបាទ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ស្តីពីការ តែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការប្រព្រឹត្តិទៅ នៃ ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញព្រះរាជក្រឹត្យលេខ ៣៧ អនក្រ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ១៩៩៥ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតគណៈកម្មការថែទាំសុខភាពបឋម
- បានឃើញតំរូវការចាំបាច់របស់ក្រសួងអភិវឌ្ឍន៍ជនបទ

### សំរេច

**ប្រការ ១ :** តែងតាំងមន្ត្រីរាជការជាន់ខ្ពស់ ០២ រូប ដែលមាននាមដូចខាងក្រោម អោយទទួលភារកិច្ចជាអចិន្ត្រៃយ៍ក្នុងលេខាធិការដ្ឋាន គណៈកម្មការ នៃការថែទាំសុខភាពបឋម តាមឋានានុក្រមដូចតទៅ :

១–ឯកឧត្តម **ទី ចំរុងផល** ជាអនុប្រធាន

២–លោក **ខា សំណាង** ជាសមាជិក

**ប្រការ ២ :** ខុទ្ទកាល័យ អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន គ្រប់មន្ទីរអភិវឌ្ឍន៍ជនបទ ខេត្ត-ក្រុង និងសាមីជន មានភារកិច្ចអនុវត្តតាម ប្រកាសនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

វេជ្ជ.ហុង ស៊ុនហួត

* * *

## ៩– ទីស្តីការ ក្រសួងធម្មការ និងសាសនា

## ប្រកាស

ភ្នំពេញ ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ១៩៩៥

**ប្រកាសលេខ ១០៦/៩៥ កធស.ប្រក**

**ស្តីពីការទទួលស្គាល់មន្ត្រីរាជការក្នុង**

**ក្របខ័ណ្ឌមន្ទីរធម្មការ និងសាសនា ខេត្តតាកែវ**

**រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១-១១-១៩៩២
- បានឃើញច្បាប់ស្តីពីការបង្កើតទីស្តីការរដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ១៧ ក្រ ចុះថ្ងៃទី ០៨ កុម្ភៈ ១៩៩២ ។
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃក្រសួងធម្មការ និងសាសនា ។

- បានឃើញប្រកាសលេខ ១៩៨ សកប ចុះថ្ងៃទី ១២ ខែ មេសា ឆ្នាំ ១៩៩៥ របស់ក្រសួងសុខាភិបាល ។

**សម្រេច**

**ប្រការ ១ :** យល់ព្រមទទួលលោក **ខា ចណ្ណា** និងលោក **ឌី សារឿន** ធ្វើការនៅមន្ទីរសុខាភិបាលខេត្ត តាកែវ អោយទៅបំរើការនៅមន្ទីរធម្មការ និងសាសនាខេត្តតាកែវ។

**ប្រការ ២ :** បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗ អាស្រ័យដោយមន្ទីរធម្មការ និងសាសនាខេត្តតាកែវជាអ្នកទទួលចាត់ចែង និងរ៉ាប់រង ។

**ប្រការ ៣ :** មន្ទីរធម្មការ និងសាសនាខេត្ត មន្ទីរផែនការ មន្ទីរហិរញ្ញវត្ថុខេត្តតាកែវ និងសាមីខ្លួនត្រូវអនុវត្តរៀងៗខ្លួន តាមប្រកាសនេះ ។

**ប្រការ ៤ :** សេចក្តីប្រកាសនេះមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា

ហត្ថលេខា និង ត្រា

**ហឿន ចណ្ណារ័ត្ន**

* * *

ភ្នំពេញ ថ្ងៃទី ៣០ ខែ ០៥ ឆ្នាំ ១៩៩៥

**ប្រកាសលេខ ១០៧/៩៥ កធស.ប្រក**

**ស្តីពីការផ្ទេរមន្ត្រីរាជការក្នុង**

**ក្របខ័ណ្ឌក្រសួងធម្មការ និងសាសនា**

**រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១-១១-១៩៩២

- បានឃើញច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ១៧ ក្រ ចុះថ្ងៃទី ០៨ កុម្ភៈ ១៩៩២ ។
- បានឃើញ អនុក្រឹត្យលេខ ២២ អនក្រ ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩២ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃក្រសួងធម្មការ និងសាសនា ។
- បានឃើញពាក្យសុំផ្លាស់របស់លោក ជូ សុភាព និងលោក ហែម ជិត ចុះថ្ងៃទី ២២ ឧសភា ឆ្នាំ ១៩៩៥ និងចំណារយល់ព្រមពីឯកឧត្តម រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា នៅថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ១៩៩៥ ។

**សម្រេច**

**ប្រការ ១** : លោក **ជូ សុភាព** លោក **ហែម ជិត** បច្ចុប្បន្នជាបុគ្គលិកក្រសួងធម្មការ និងសាសនា ត្រូវផ្ទេរអោយទៅធ្វើការនៅមន្ទីរធម្មការ និងសាសនាខេត្តពោធិ៍សាត់ ។

**ប្រការ ២** : បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗ របស់លោក ជូ សុភាព និងលោក ហែម ជិត ជូនមន្ទីរធម្មការ និងសាសនាខេត្ត ពោធិ៍សាត់ ។

**ប្រការ ៣** : មន្ទីរធម្មការ និងសាសនាខេត្តពោធិ៍សាត់ លោក ជូ សុភាព និងលោក ហែម ជិត ត្រូវអនុវត្តតាមប្រកាសនេះរៀងៗខ្លួន ។

**ប្រការ ៤** : សេចក្តីប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនា

ហត្ថលេខា និងត្រា

**ហៀង វណ្ណារិទ្ធ**

* * *

## ១០— ទីស្តីការគណៈរដ្ឋមន្ត្រី យុត្តិធម៌សង្គម

**ប្រកាស**

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ១៩៩៥

**ប្រកាសលេខ ១២៣/៩៥ យធប្រក**

**ស្តីពីការតែងតាំងមន្ត្រីរាជការរបស់យុត្តិធម៌សង្គម**

## រដ្ឋមន្ត្រីប្រតិភូ ទទួលបន្ទុកគ្រប់គ្រងយុវនិតិសម្បទា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យព្រះករុណាជាម្ចាស់ជីវិតលើត្បូង ចុះថ្ងៃទី ០៨ កុម្ភៈ ១៩៩៤ ត្រាស់បង្គាប់ តែងតាំងប្រតិភូ នៃរាជរដ្ឋាភិបាល ទទួលបន្ទុកដឹកនាំមជ្ឈមណ្ឌលគ្រប់គ្រងយុវទោសករ
- បានឃើញ អនុក្រឹត្យ លេខ ១៧ អនក្រ ចុះថ្ងៃទី ១៩ មេសា ១៩៩៤ របស់រាជរដ្ឋាភិបាល ស្តីពីតួនាទីភារកិច្ច និងរចនាសម្ព័ន្ធរបស់មជ្ឈមណ្ឌលគ្រប់គ្រងយុវទោសករ
- យោងការងារចាំបាច់ របស់ទីស្តីការរដ្ឋមន្ត្រីយុវនិតិសម្បទា

**សម្រេច**

**ប្រការ ១** : តែងតាំងមន្ត្រីរាជការមួយចំនួន ជាប្រធាន និងជាអនុប្រធានមណ្ឌល :

- លោក **អ៊ុក សារឈី** ប្រធាន ឋានៈស្មើអនុប្រធាននាយកដ្ឋាន
- លោក **ខៀវ ចំរើន** អនុប្រធាន ឋានៈស្មើប្រធានការិយាល័យ
- លោក **សាំង នៅ** អនុប្រធាន ឋានៈស្មើប្រធានការិយាល័យ

**ប្រការ ២** : នាយកខុទ្ទកាល័យ នាយកដ្ឋានបណ្តុះបណ្តាល នាយកដ្ឋានគ្រប់គ្រង នាយកដ្ឋានទំនាក់ទំនងជំនួយ និងសាមីខ្លួន ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ញ៉ឹម វណ្ណដា**

* * *

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ១៩៩៥

**ប្រកាសលេខ ១២៤/៩៥ យ.ន.ប្រ.ក**

**ស្តីពីការតែងតាំងមន្ត្រីរាជការ**

**របស់យុទ្ធនិតិសម្បទា**

**រដ្ឋមន្ត្រីប្រតិភូ ទទួលបន្ទុកគ្រប់គ្រងយុទ្ធនិតិសម្បទា**

**សម្រេច**

**ប្រការ ១** : តែងតាំងមន្ត្រីរាជការថ្នាក់ការិយាល័យ នៃខុទ្ទកាល័យ និងនាយកដ្ឋានមួយចំនួន :

**ខុទ្ទកាល័យ**

| | | |
|---|---|---|
| ការិយាល័យគណនេយ្យ : | លោក **ឡាំ ហេងហួត** | ប្រធាន |
| | លោក **ទូច សើ** | អនុប្រធាន |
| | លោក **ខៀវ ចំនួមុនី** | អនុប្រធាន |
| ការិយាល័យបុគ្គលិក : | លោក **អ៊ូ ចាន់ឌី** | ប្រធាន |
| | លោក **ចៅ ឆេង** | អនុប្រធាន |
| ការិយាល័យរដ្ឋបាល : | លោក **លុក ម៉ុនថា** | អនុប្រធាន |
| លេខាធិការដ្ឋាន : | លោក **ឃឿង ខ្លួត** | ប្រធាន |

**នាយកដ្ឋានគ្រប់គ្រង**

| | | |
|---|---|---|
| ការិយាល័យនិតិកម្ម | : លោក **សួស នំលួ** | អនុប្រធាន |
| ការិយាល័យកោសល្យវិច័យ | : លោក **ស៊ី ស៊ីថា** | អនុប្រធាន |
| ការិយាល័យចិត្តសាស្ត្រ | : លោក **មាស ញឹម** | អនុប្រធាន |
| នាយកដ្ឋានបណ្តុះបណ្តាល | | |
| ការិយាល័យបំពេញវិជ្ជា | : លោក **អ៊ូ ហៀង** | អនុប្រធាន |
| ការិយាល័យអប់រំសតិអារម្មណ៍ | : លោក **ជា ម៉ៃ** | អនុប្រធាន |

ការិយាល័យបណ្ដុះបណ្ដាលវិជ្ជាជីវៈ : លោក ពៅ សុផាត អនុប្រធាន

នាយកដ្ឋានទំនាក់ទំនងជំនួយ

ការិយាល័យទាក់ទងបរទេស : លោក គីម ចិមុយឫទ្ធិ ប្រធាន

ការិយាល័យទទួលជំនួយ : លោក នាង កាំផុល អនុប្រធាន

**ប្រការ ២ :** នាយកខុទ្ទកាល័យ នាយកដ្ឋានបណ្ដុះបណ្ដាល នាយកដ្ឋានគ្រប់គ្រង នាយកដ្ឋានទំនាក់ទំនងជំនួយ និង សាមីខ្លួន ត្រូវអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ញឹម វណ្ណដា**

* * *

## ១១— រដ្ឋលេខាធិការដ្ឋាន កិច្ចការនារី

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ១៩៩៥

**ប្រកាសលេខ ៥២២ អគន**

**ស្ដីពីការផ្ទេរមន្ត្រីរាជការ**

**រដ្ឋលេខាធិការកិច្ចការនារី**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ។
- បានឃើញសំណើរបស់សាមីខ្លួន ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ១៩៩៥ ។

– បានឃើញ ចំណារយល់ព្រមរបស់នាយកមជ្ឈមណ្ឌលស្ត្រីក្នុងអភិវឌ្ឍន៍ខេត្ត សៀមរាប លេខ ៣៧ មសអ.ខ ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ។

**សម្រេច**

**ប្រការ ១** : ផ្ទេរអ្នកស្រី អ៊ី រិន និងក្របខ័ណ្ឌមួយកន្លែងអោយទៅបំពេញការងារនៅមជ្ឈមណ្ឌលស្ត្រីក្នុងអភិវឌ្ឍន៍ ខេត្ត សៀមរាប ។

**ប្រការ ២** : ប្រាក់បៀវត្សរ៍ និងប្រាក់ឧបត្ថម្ភផ្សេងៗ ទៀតរបស់សាមីខ្លួន ត្រូវបានអនុវត្តនៅអង្គភាពថ្មី បន្ទាប់ពីបានទទួលការផ្តាច់ប្រាក់ពីរដ្ឋលេខាធិការដ្ឋានកិច្ចការនារី ។

**ប្រការ ៣** : លោកស្រី អគ្គនាយកទាំងពីរ នាយកខុទ្ទកាល័យ នាយកថវិកា–គណនេយ្យ និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តតាមខ្លឹមសារ នៃប្រកាសនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃដែលបានចុះហត្ថលេខាតទៅ ។

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

**កៀវ កុសល**

* * *

បោះពុម្ពនៅរោងពុម្ពទីស្តីការគណៈរដ្ឋមន្ត្រី
លើកទី ១ ចំនួន ២៨០០ ច្បាប់

តម្លៃ ១១៩០